ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## រាជរដ្ឋាភិបាលកម្ពុជា

# កម្មវិធីពិសេសជំរុញការវិនិយោគ
# ក្នុងខេត្តទាំងបួននៅភូមិភាគឦសាន នៃព្រះរាជាណាចក្រកម្ពុជា
# ឆ្នាំ ២០២៥-២០២៨




រៀបចំដោយ គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ខែមករា ឆ្នាំ២០២៥

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# រាជរដ្ឋាភិបាលកម្ពុជា

# កម្មវិធីពិសេសជំរុញការវិនិយោគក្នុងខេត្តទាំងបួន
# នៅភូមិភាគឦសាន នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០២៥-២០២៨

ខែ មករា ឆ្នាំ ២០២៥

# អារម្ភកថា

ការគិតគូរលើការអភិវឌ្ឍប្រកបដោយចីរភាព និងមានបរិយាប័ន្ន និងកិច្ចខិតខំប្រឹងប្រែងបែង-ចែកភាគលាភនៃកំណើនសេដ្ឋកិច្ច គឺជាចំណោទបញ្ហាដែលរដ្ឋាភិបាលនៅលើពិភពលោកត្រូវយកចិត្ត-ទុកដាក់ជាប្រចាំ។ បន្ទាប់ពីកម្ពុជាទទួលបានសន្តិភាពពេញលេញនៅឆ្នាំ ១៩៩៨ តាមរយៈភាពជោគជ័យនៃ**នយោបាយ ឈ្នះ-ឈ្នះ** ដែលបានផ្ដួចផ្ដើម និងអនុវត្ត ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងជាអតីតនាយករដ្ឋមន្ត្រី, ភាគលាភនៃសន្តិភាពបានផ្តល់លទ្ធភាពឱ្យរាជរដ្ឋាភិបាល អាចប្រមូលផ្តុំធនធានភាគច្រើនដើម្បីចំណាយលើការអភិវឌ្ឍនៅគ្រប់វិស័យ។ សមិទ្ធផលរបស់រាជរដ្ឋាភិបាលអាណត្តិមុនៗ ដែលបានកើតឡើងតាមរយៈការអនុវត្តដោយជោគជ័យនៃ **យុទ្ធសាស្ត្រត្រីកោណ** និង **យុទ្ធសាស្ត្រចតុកោណ** ទាំង ៤ ដំណាក់កាល, បានផ្លាស់ប្តូរមុខមាត់កម្ពុជា គួរឱ្យកត់សម្គាល់លើគ្រប់ទិដ្ឋភាព ហើយសូចនាករសេដ្ឋកិច្ច-សង្គម ជាច្រើនត្រូវបានកែលម្អ ប្រកបដោយមោទនភាព។ លើសពីការបង្កើតសន្តិភាព និងអភិវឌ្ឍសេដ្ឋកិច្ចជាតិខ្លួន, តួនាទីរបស់កម្ពុជា នៅក្នុងរបៀបវារៈនៃការកសាងសន្តិភាព និងជំរុញការអភិវឌ្ឍប្រកបដោយចីរភាពនៅក្នុងតំបន់ ក៏មានការទទួលស្គាល់ជាអន្តរជាតិ។ ទាំងនេះគឺជាមត៌កនៃការកសាងជាតិ ដែលរាជរដ្ឋា-ភិបាលនីតិកាលទី ៧ នៃរដ្ឋសភា ត្រូវបន្តថែរក្សា និងពង្រឹងបន្ថែមទៀត តាមរយៈការដាក់ចេញនូវ **យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី ១** ដើម្បីបន្តដឹកនាំប្រទេសកម្ពុជា ឱ្យកាន់តែសម្បូរសប្បាយរុងរឿង ស្របតាម **ចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០**។

ពិតណាស់ថា ធនធានរបស់យើងមានកំណត់ ដូច្នេះ ល្បឿននៃការអភិវឌ្ឍ និងរបាយនៃការ-អភិវឌ្ឍ ពុំអាចកើតមានឡើងស្មើៗគ្នា នៅទូទាំងប្រទេសភ្លាមៗ តាមអ្វីដែលយើងចង់បាននោះឡើយ។ តំបន់ដែលនៅឆ្ងាយៗ ជាពិសេស តំបន់ភូមិភាគឦសាន រួមមាន ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្ត-រតនគិរី និងខេត្តមណ្ឌលគិរី ទាមទារឱ្យមានការគិតគូរជាពិសេសដោយឡែក។ តំបន់ភូមិភាគឦសាន គឺជាតំបន់ដែលមានវិសាលភាពដីបង្កបង្កើនផលធំទូលាយ និងសម្បូរទៅដោយធនធានធម្មជាតិ។ ក្នុងអាណត្តិមុនៗ, រាជរដ្ឋាភិបាលបានខិតខំយកចិត្តទុកដាក់លើការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ដើម្បីតភ្ជាប់តំបន់នេះដែលនៅឆ្ងាយពីមជ្ឈមណ្ឌលនៃកំណើន ឬប៉ូលសេដ្ឋកិច្ចសំខាន់ៗ។ ហេដ្ឋារចនាសម្ព័ន្ធទាំងនោះ បានរួមចំណែកយ៉ាងសំខាន់នៅក្នុងការជួយសម្រួលដល់ការតភ្ជាប់តំបន់នេះ ជាមួយនឹងចរន្តសេដ្ឋកិច្ច និងពាណិជ្ជកម្មផ្ទៃក្នុងប្រទេស ក៏ដូចជាជាមួយបណ្តាប្រទេសជាប់ព្រំដែន។ ដើម្បីបង្កើនចរន្តសេដ្ឋកិច្ចសម្រាប់តំបន់នេះបន្ថែមទៀត, កាលពីខែសីហា ឆ្នាំ២០២៤ ខ្ញុំបានអំពាវនាវឱ្យវិស័យឯកជនបង្កើនការវិនិយោគឱ្យបានច្រើន តាមដែលអាចធ្វើទៅបាន ហើយបានណែនាំឱ្យគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (គ.ស.ហ.) ដែលមាន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាប្រធាន, ដឹកនាំរៀបចំការសិក្សា និងបង្កើតកម្មវិធីពិសេសមួយសម្រាប់តំបន់ភូមិភាគឦសាន។

«**កម្មវិធីពិសេសជំរុញការវិនិយោគក្នុងខេត្តទាំងបួននៅភូមិភាគឦសាននៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០២៥-២០២៨**» គឺជាលទ្ធផលនៃការសិក្សា ដែលមានការចូលរួមផ្តល់ធាតុចូល និងការពិគ្រោះយោបល់គ្រប់ជ្រុងជ្រោយ ពីសំណាក់ភាគីពាក់ព័ន្ធជាច្រើន

ទាំងក្នុងកម្រិតជាតិ និងថ្នាក់ក្រោមជាតិនៃវិស័យសាធារណៈ, ព្រមទាំងភាគីជាច្រើននៃវិស័យឯកជន ក៏ដូចជាប្រជាសហគមន៍។ កម្មវិធីពិសេសនេះ គឺជាឯកសារដ៏មានសារៈសំខាន់ នៅក្នុងការចង្អុលបង្ហាញវិស័យអាទិភាពចំនួន ៣ គឺកសិកម្ម កសិ-ឧស្សាហកម្ម និងទេសចរណ៍ ដែលស្របតាមទាយជ្ជ-ទានដែលមានស្រាប់របស់ខេត្តទាំងបួន ដែលគួរជំរុញការវិនិយោគបន្ថែម ដោយមានការគាំទ្រយ៉ាងទូលំទូលាយពីរាជរដ្ឋាភិបាល។ កម្មវិធីពិសេសនេះបានគូសបញ្ជាក់យ៉ាងច្បាស់នូវការលើកទឹកចិត្តដ៏ច្រើនដែលរាជរដ្ឋាភិបាលអាចផ្តល់ជូនវិស័យឯកជន ហើយក៏មានការគិតគូរពីការផ្តល់ហិរញ្ញប្បទានដែលមានអត្រាការប្រាក់សមរម្យ, ការជួយកាត់បន្ថយថ្លៃដើមផលិតកម្ម,ការសម្រួលនីតិវិធី និងការគាំទ្រសកម្មភាពវិនិយោគឯកជនផងដែរ។

ក្នុងន័យនេះ, ខ្ញុំសូមកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះ **ឯកឧត្តមអគ្គបណ្ឌិតសភា-ចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាន គ.ស.ហ. ដែលបានដឹកនាំរៀបចំកម្មវិធីពិសេសនេះឡើង។ ខ្ញុំក៏សូមថ្លែងអំណរគុណដល់ការសហការគាំទ្រប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ពីសំណាក់ថ្នាក់ដឹកនាំនៃក្រសួង-ស្ថាប័ន និងភាគីពាក់ព័ន្ធទាំងអស់ ដែលបានរួមចំណែកធ្វើឱ្យការរៀបចំកម្មវិធីពិសេសនេះ កាន់តែមានភាពជាក់ស្តែងនិយម, ចំគោលដៅ និងអាចអនុវត្តបាន។

ជាទីបញ្ចប់, ខ្ញុំសូមប្រកាសដាក់ឱ្យប្រើប្រាស់ «**កម្មវិធីពិសេសជំរុញការវិនិយោគក្នុងខេត្តទាំងបួននៅតំបន់ភាគពាយ័ព្យសាន នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០២៥-២០២៨**» និងស្នើឱ្យគ្រប់ស្ថាប័នពាក់ព័ន្ធទាំងអស់ ចូលរួមអនុវត្តកម្មវិធីពិសេសនេះ ប្រកបដោយស្មារតីទទួលខុសត្រូវ, និងមានភាពម្ចាស់ការ ដើម្បីសម្រេចជោគជ័យ ស្របតាមគោលបំណង និងគោលដៅដែលបានដាក់ចេញ ដើម្បីជំរុញកំណើនសេដ្ឋកិច្ច និងភាពរីកចម្រើនរុងរឿង ប្រកបដោយបរិយាប័ន្ន នៅក្នុងបណ្តាខេត្តនៅជាប់ព្រំដែន ក្នុងដំណើរប្រកបដោយក្តីសង្ឃឹមរបស់កម្ពុជា ឆ្ពោះទៅរកចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០។

ថ្ងៃសុក្រ ១៤ រោច ខែ ផល្គុន ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨

នៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

# មាតិកា


**អារម្ភកថា** ........ ១

**១. សេចក្តីផ្តើម** ........ ៣

**២. ទិដ្ឋភាពទូទៅនៃបណ្តាខេត្តក្នុងតំបន់ភូមិភាគឦសាន** ........ ៤

២.១ ខេត្តក្រចេះ ........ ៤

២.២ ខេត្តស្ទឹងត្រែង ........ ៥

២.៣ ខេត្តរតនគិរី ........ ៥

២.៤ ខេត្តមណ្ឌលគិរី ........ ៦

**៣. សក្តានុពល និងបញ្ហាប្រឈមចម្បងៗ** ........ ៦

៣.១ សក្តានុពល ........ ៦

៣.២ បញ្ហាប្រឈមចម្បងៗ ........ ៧

**៤. គោលគំនិត «៣.៣.៣» នៃការរៀបចំកម្មវិធីពិសេស** ........ ៨

៤.១ ទស្សនាទាន ៣ ........ ៨

៤.២ វិស័យអាទិភាព ៣ ........ ៨

៤.៣ វិធានការគាំទ្រ និងជំរុញការវិនិយោគ ៣ ប្រភេទ ........ ៩

**៥. វិធានការ និងលក្ខខណ្ឌវិនិច្ឆ័យទទួលបានការគាំទ្រ និងជំរុញការវិនិយោគ** ........ ៩

**៦. យន្តការអនុវត្ត, តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ** ........ ១៤

**៧. សេចក្តីសន្និដ្ឋាន** ........ ១៥

**៨. ឧបសម្ព័ន្ធអំពីវិធានការគាំទ្រ និងជំរុញការវិនិយោគ** ........ ១៧

## ១. សេចក្ដីផ្ដើម

ក្រោមម្លប់ដ៏សែនត្រជាក់នៃសុខសន្តិភាពពេញបរិបូរណ៍ ដែលកម្ពុជាទទួលបាននៅឆ្នាំ ១៩៩៨ តាមរយៈ **នយោបាយឈ្នះ-ឈ្នះ** របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងអតីតនាយករដ្ឋមន្ត្រី, នាវាកម្ពុជាបានបោះពួយយ៉ាងលឿន លើមាគ៌ានៃការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ប្រកបដោយភាពវិជ្ជមាន និងក្តីសង្ឃឹម។ សន្តិភាពបានអនុញ្ញាតឱ្យរាជរដ្ឋាភិបាលមានលទ្ធភាពផ្តោតការយកចិត្តទុកដាក់លើការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ជាមួយនឹងការដាក់ចេញ និងអនុវត្តប្រកបដោយប្រសិទ្ធភាព និងសង្គតិភាព នូវគោលនយោបាយអភិវឌ្ឍន៍ជាតិសំខាន់ៗជាបន្តបន្ទាប់គួយ៉ាងដូចជា យុទ្ធសាស្ត្រត្រីកោណ យុទ្ធសាស្ត្រចតុកោណទាំង ៤ ដំណាក់កាល ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជា និងកម្មវិធីកែទម្រង់សំខាន់ៗ សំដៅលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ក្រោមការដឹកនាំដ៏ប៉ិនប្រសប់របស់ **សម្តេចអគ្គមហាសេនា-បតីតេជោ ហ៊ុន សែន**។ មរតកសន្តិភាព ក្នុងរយៈពេលជាង ២០ ឆ្នាំកន្លងមក គឺជាបុព្វលក្ខខណ្ឌ និងមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ហើយផ្លែផ្កាទាំងនេះបានហុចផលដល់ប្រជាជនកម្ពុជា តាមរយៈវឌ្ឍនភាពនៃសូចនាករសេដ្ឋកិច្ច-សង្គម លើគ្រប់វិស័យ។

រាជរដ្ឋាភិបាលក្នុងនីតិកាលទី ៧ នៃរដ្ឋសភា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងថាមវន្តរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** បានដាក់ចេញនូវ **«យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី ១»** សំដៅបន្តកសាងមូលដ្ឋានសេដ្ឋកិច្ច-សង្គមកម្ពុជា ឆ្ពោះទៅសម្រេចបានចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០។ ក្នុងនោះផងដែរ, បញ្ចកោណទី២ បានគូសរំលេចពីសារៈសំខាន់នៃ **«ការធ្វើ-ពិពិធកម្មសេដ្ឋកិច្ច និងការបង្កើនភាពប្រកួតប្រជែង»** ហើយមុំទី១ បានផ្តោតការយកចិត្តទុកដាក់លើ **«ការអភិវឌ្ឍវិស័យគន្លឹះ និងប្រភពថ្មីនៃកំណើនសេដ្ឋកិច្ច»**។

ផ្អែកលើស្មារតីនេះ, រាជរដ្ឋាភិបាលបានរៀបចំ និងដាក់ចេញនូវ **«កម្មវិធីពិសេសជំរុញការវិនិយោគក្នុងខេត្តទាំងបួននៅភូមិភាគឦសាន នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០២៥-២០២៨»** ដើម្បីដាក់ទិសដៅអាទិភាពវិនិយោគ និងអភិវឌ្ឍន៍ សម្លឹងឆ្ពោះទៅទិសឦសាន ដែលជាការគិតគូរមានលក្ខណៈជាយុទ្ធសាស្ត្រ ពោលគឺជំរុញការពង្រីកមូលដ្ឋានសេដ្ឋកិច្ចចំពោះបណ្តាខេត្តដែលនៅឆ្ងាយពីមជ្ឈមណ្ឌលកំណើន ក៏ដូចជាជំរុញការតភ្ជាប់នៃចរន្តសេដ្ឋកិច្ចជាតិ។ កម្មវិធីពិសេសនេះ នឹងក្លាយជាទិសដៅគោលនយោបាយ ដែលមានសារៈសំខាន់ មិនត្រឹមតែជំរុញការវិនិយោគ និងអភិវឌ្ឍន៍តំបន់ភូមិភាគឦសានប៉ុណ្ណោះទេ ប៉ុន្តែក៏នឹងចូលរួមពង្រីកមូលដ្ឋានសេដ្ឋកិច្ច និងការអភិវឌ្ឍវិស័យគន្លឹះ និងប្រភពកំណើនថ្មីរបស់សេដ្ឋកិច្ចជាតិជារួម ស្របតាមសេចក្តីប៉ងប្រាថ្នារបស់រាជរដ្ឋាភិបាល ដូចបានចង្អុលបង្ហាញក្នុងយុទ្ធសាស្ត្របញ្ចកោណ។

កម្មវិធីពិសេសនេះ បានកំណត់យកវិស័យអាទិភាពចំនួន ៣ គឺកសិកម្ម កសិ-ឧស្សាហកម្ម និងទេសចរណ៍ ដែលស្របតាមទាយជ្ជទានដែលមានស្រាប់របស់ខេត្តទាំងបួននៅភូមិភាគឦសាន រួមមានខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តរតនគិរី និងខេត្តមណ្ឌលគិរី។ កម្មវិធីពិសេសនេះ បានគូសបញ្ជាក់យ៉ាង

ច្បាស់នូវការលើកទឹកចិត្តដ៏ច្រើនដែលរាជរដ្ឋាភិបាលអាចផ្តល់ជូនវិស័យឯកជន ហើយក៏មានការគិតគូរពីការផ្តល់ហិរញ្ញប្បទានដែលមានអត្រាការប្រាក់សមរម្យ, ការជួយកាត់បន្ថយថ្លៃដើមផលិតកម្ម, ការសម្រួលនីតិវិធី និងការគាំទ្រសកម្មភាពវិនិយោគឯកជនផងដែរ។

## ២. ទិដ្ឋភាពទូទៅនៃបណ្តាខេត្តក្នុងតំបន់ភូមិភាគឦសាន

ខេត្តទាំងបួននៅភូមិភាគឦសានក្នុងប្រទេសកម្ពុជា (ក្រចេះ ស្ទឹងត្រែង រតនគិរី និងមណ្ឌលគិរី) ជាខេត្តដែលមានសក្តានុពល ក្នុងន័យថាខេត្តទាំងនេះមានកត្តាទាយជ្ជទាន (Factor Endowment) ដែលធ្វើឱ្យមានភាពអំណោយផលដល់វិស័យកសិកម្ម កសិ-ឧស្សាហកម្ម និងទេសចរណ៍។ ដំណាំកសិកម្ម និងកសិ-ឧស្សាហកម្មយុទ្ធសាស្ត្រក្នុងខេត្តទាំងបួន មានដូចជា៖ កៅស៊ូ ស្វាយចន្ទី ដំឡូងមី ម្រេច ស្វាយ និងចេកអំបូងលឿង ជាដើម, ដែលសុទ្ធសឹងជាផលិតផលកសិផលមានសក្តានុពលទាំងទីផ្សារនាំចេញ និងទីផ្សារក្នុងស្រុក។ ជាមួយគ្នានេះ, ភាពអំណោយផលនៃសម្បត្តិវប្បធម៌ធម្មជាតិ (ឧទា. អាកាសធាតុ ខ្យល់បរិសុទ្ធ ធនធានធម្មជាតិដ៏សម្បូរបែប, ព្រៃឈើ និងដែនជម្រកសត្វព្រៃ ជាដើម) បានធ្វើឱ្យខេត្តទាំងបួន ក្លាយជាតំបន់ដែលមានសក្តានុពលទេសចរណ៍ធម្មជាតិ និងអេកូទេសចរណ៍ផងដែរ។ ទោះជាយ៉ាងនេះ, ខេត្តទាំងនេះក៏នៅតែមានបញ្ហាប្រឈមជារចនាសម្ព័ន្ធមួយចំនួន ដែលតម្រូវឱ្យរាជរដ្ឋាភិបាលបន្តគិតគូរ និងដោះស្រាយ ដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ចខេត្ត ដោយផ្អែកលើកត្តាទាយជ្ជទាន។

### ២.១ ខេត្តក្រចេះ

ខេត្តក្រចេះមានផ្ទៃដី ១១ ០៩៤ គីឡូម៉ែត្រការ៉េ និងចែកជា ៦ ស្រុក (ស្រុកស្នួល ស្រុកសំបូរ, ស្រុកព្រែកប្រសព្វ ស្រុកចិត្របុរី ស្រុកឆ្លូង និងស្រុកអូរគ្រៀងសែនជ័យ) និង ក្រុងចំនួន ១ (ក្រុងក្រចេះ)។ ផ្អែកតាមទិន្នន័យឆ្នាំ ២០២៣ ខេត្តក្រចេះមានប្រជាជនសរុប ៤៤៧ ៣៣០ នាក់ និងដង់ស៊ីតេប្រជាជន ៤០ នាក់/គីឡូម៉ែត្រការ៉េ។ សេដ្ឋកិច្ចនៃខេត្តនេះ ពឹងអាស្រ័យលើវិស័យកសិកម្ម កសិ-ឧស្សាហកម្ម និងទេសចរណ៍ ជាចម្បង។ ចំពោះវិស័យកសិកម្ម ខេត្តក្រចេះមានផ្ទៃដីដាំដុះសរុប ១៧០ ៦២៨ ហិកតា ដែលក្នុងនោះដំណាំចម្បងៗ រួមមាន៖ ដំឡូងមី (១ ៥២៩ ៦៩១ តោន) ស្រូវ (១៨១ ០៦៤ តោន) ស្វាយចន្ទី (៩៣ ០៣០ តោន) កៅស៊ូ (៧៥ ៦៥៤ តោន) និងដំណាំឈើហូបផ្លែដូចជា ចេកអំបូងលឿង (៤៩ ១២០ តោន) ខ្នុរ (១២ ៩៦០ តោន) និងក្រូចថ្លុង (៩ ៣១០ តោន)។ ខេត្តក្រចេះ មានតំបន់សេដ្ឋកិច្ចពិសេសមួយនៅស្រុកស្នួល (តំបន់សេដ្ឋកិច្ចពិសេស យូ ប៊ី អ៊ី ស្នួល) ជិតព្រំដែនកម្ពុជា-វៀតណាម ដែលជាតំបន់ឧស្សាហកម្មចម្បងសម្រាប់ខេត្តភូមិភាគឦសាន។ តំបន់សេដ្ឋកិច្ចពិសេសនេះមានទំហំ ៨១៧ ហិកតា និងមានក្រុមហ៊ុនសរុបចំនួន ៧ ដែលក្នុងនោះ ក្រុមហ៊ុនកំពុងដំណើរការ និងសាងសង់មានចំនួន ៣ (ក្រុមហ៊ុនផលិតសំបកកង់យានយន្តចំនួន ២, និងក្រុមហ៊ុនផលិតចំហាយទឹក និងខ្យល់ក្តៅចំនួន ១)។ ចំពោះវិស័យទេសចរណ៍, ខេត្តក្រចេះសម្បូរទៅដោយរមណីយដ្ឋានទេសចរណ៍ធម្មជាតិ និងវប្បធម៌ ដែលបច្ចុប្បន្នមានចំនួន ២៤ កន្លែង។ រមណីយដ្ឋានអន្លង់ផ្សោត និងរមណីយដ្ឋានទឹកជ្រោះកាំពី សុទ្ធសឹងជាតំបន់ទេសចរណ៍ដែលមានការពេញនិយមក្នុងខេត្ត។ ទន្ទឹមនេះ, តំបន់ទេសចរណ៍បែបសហគមន៍លើកោះ សុទ្ធសឹងជាតំបន់សក្តានុពលដែល

អាចអភិវឌ្ឍបន្ថែម។ ក្នុងឆ្នាំ ២០២៣, មានភ្ញៀវទេសចរ ២៣៣ ៤៦១ នាក់ បានមកកម្សាន្តនៅខេត្តក្រចេះ ដោយក្នុងនោះ ២១៩ ៨៩២ នាក់ ជាភ្ញៀវជាតិ និង ១៣ ៥៦៩ នាក់ ជាភ្ញៀវអន្តរជាតិ។

## ២.២ ខេត្តស្ទឹងត្រែង

ខេត្តស្ទឹងត្រែងមានផ្ទៃដី ១២ ០១៦ គីឡូម៉ែត្រការ៉េ និងចែកជា ៥ ស្រុក (ស្រុកថាឡាបរិវ៉ាត់, ស្រុកសេសាន ស្រុកសៀមប៉ាង ស្រុកសៀមបូក និងស្រុកបូរីអូរស្វាយសែនជ័យ) និង ក្រុងចំនួន ១ (ក្រុងស្ទឹងត្រែង)។ ខេត្តនេះមានប្រជាជនសរុបចំនួន ១៨៣ ៥៦៨ នាក់ (ឆ្នាំ ២០២៣) និងដង់ស៊ីតេប្រជាជន ១៥,៣ នាក់/គីឡូម៉ែត្រការ៉េ។ សេដ្ឋកិច្ចនៃខេត្តស្ទឹងត្រែង ពឹងអាស្រ័យលើវិស័យកសិកម្មជាចម្បង។ ផ្ទៃដីដាំដុះសរុបក្នុងខេត្តមានចំនួន ១៥០ ៣៦៧ ហិកតា និងមានកសិផលសំខាន់ៗដូចជា៖ ដំឡូងមី (៥៩៩ ០៩៧ តោន) ស្រូវ (៧២ ២៧០ តោន) ស្វាយចន្ទី (៤៧ ៣៨៨ តោន) កៅស៊ូ(៧ ៤៤២ តោន) និងចេកអំបូងលឿង (៤៨ ០០០ តោន)។ ទន្ទឹមនេះ, វិស័យទេសចរណ៍ក៏ជាវិស័យសក្តានុពលផងដែរ ដោយខេត្តស្ទឹងត្រែងមានទន្លេចំនួន ៤ ហូរកាត់ (ទន្លេមេគង្គ ទន្លេសេកុង ទន្លេសេសាន និងទន្លេស្រែពក) ដែលបង្កជាលក្ខណៈអំណោយផលដល់ទេសចរណ៍ធម្មជាតិតាមដងទន្លេ។ ជាក់ស្តែង, ក្នុងឆ្នាំ២០២៣ មានភ្ញៀវទេសចរជាង ៤២ ១២៨ នាក់ បានមកកម្សាន្តនៅខេត្តស្ទឹងត្រែង ដោយក្នុងនោះ ៤១ ៣២១ នាក់ ជាភ្ញៀវជាតិ និង ៨០៧ នាក់ ជាភ្ញៀវអន្តរជាតិ។ ដោយឡែក, តំបន់ទេសចរណ៍ក្នុងខេត្តនៅពុំទាន់ត្រូវបានអភិវឌ្ឍឱ្យបានអស់សក្តានុពលនៅឡើយ ដែលមានរមណីយដ្ឋានទេសចរណ៍ ដូចជា តំបន់ឧទ្យានជាតិវីរៈជ័យ, សហគមន៍អេកូទេសចរណ៍ត្បូងខ្លា, តំបន់រ៉ាមសារមេគង្គ និងតំបន់ទេសចរណ៍ធម្មជាតិផ្សេងៗដែលមានសម្រស់ស្អាត និងគួរជាទីមនោរម្យចំពោះភ្ញៀវទេសចរបែបធម្មជាតិ ប៉ុន្តែនៅខ្វះខាតហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ និងធនធានហិរញ្ញវត្ថុក្នុងការអភិវឌ្ឍ។

## ២.៣ ខេត្តរតនគិរី

ខេត្តរតនគិរី ជាតំបន់ភ្នំ ដែលមានផ្ទៃដីសរុប ១០ ៧៨២ គីឡូម៉ែត្រការ៉េ ចែកចេញជា ៨ ស្រុក (ស្រុកកូនមុំ ស្រុកអូរយ៉ាដាវ ស្រុកបរកែវ ស្រុកលំផាត់ ស្រុកអូរជុំ ស្រុកវើនសៃ ស្រុកអណ្តូងមាស និង ស្រុកតាវែង) និង ក្រុងចំនួន ១ (ក្រុងបានលុង)។ ខេត្តរតនគិរី មានប្រជាជនសរុបចំនួន ២៣១ ០២៧ នាក់ (ឆ្នាំ ២០២៣) និងមានដង់ស៊ីតេប្រជាជនចំនួន ២១,៤៣ នាក់/គីឡូម៉ែត្រការ៉េ។ សេដ្ឋកិច្ចនៃខេត្តរតនគិរីមួយផ្នែកធំ គឺផ្អែកលើវិស័យកសិកម្ម កសិ-ឧស្សាហកម្ម និងវិស័យទេសចរណ៍។ ចំពោះវិស័យកសិកម្ម ខេត្តរតនគិរីមានផ្ទៃដីដាំដុះសរុបចំនួន ១១៨ ៨២៧ ហិកតា។ ដំណាំសំខាន់ៗដែលខេត្តនេះ ផលិតបានក្នុងឆ្នាំ ២០២៣ រួមមាន៖ ដំឡូងមី (៤២៥ ៧៦៨ តោន) ចេកអំបូងលឿង (១៦១ ៧៥៤ តោន) កៅស៊ូ (៦៥ ៤៦០ តោន) និងស្វាយចន្ទី (៣៥ ១៨១ តោន)។ ក្នុងវិស័យកសិ-ឧស្សាហកម្ម ខេត្តនេះមានរោងចក្រចំនួន ៨ រោងចក្រ ក្នុងនោះមាន រោងចក្រកែច្នៃកៅស៊ូ (៤) រោងចក្រកែច្នៃចេក (២) រោងចក្រដំឡូងមី (១) និងរោងចក្រកែច្នៃចម្រុះ កៅស៊ូ ដូងប្រេង និងផ្លែឈើ (១) រួមទាំងសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្មជាច្រើនទៀត។ ចំណែកវិស័យទេសចរណ៍, ខេត្តរតនគិរី មានរមណីយដ្ឋានទេសចរណ៍សរុប ២៧ កន្លែង រួមមាន រមណីយដ្ឋានទេសចរណ៍ធម្មជាតិ

(២០ កន្លែង) រមណីយដ្ឋានវប្បធម៌ (២ កន្លែង) និងរមណីយដ្ឋានកែច្នៃ (៥ កន្លែង)។ លើសពីនេះ, ខេត្តរតនគិរី ក៏មាននូវវប្បធម៌ជនជាតិដើមភាគតិចដែលជាចំណុចទាក់ទាញសម្រាប់ទេសចរណ៍វប្បធម៌។ យោងតាមទិន្នន័យក្នុងឆ្នាំ ២០២៣, ខេត្តរតនគិរី ទទួលបានភ្ញៀវទេសចរជាតិចំនួន ៧ ៨១៥ នាក់ និងភ្ញៀវទេសចរអន្តរជាតិចំនួន ២៩៣ ០៨៩ នាក់។ ជារួម, ខេត្តរតនគិរីមានសក្តានុពលលើដំណាំកសិ-ឧស្សាហកម្ម និងទេសចរណ៍ធម្មជាតិដែលអាចកែច្នៃបន្ថែមបាន ដើម្បីជំរុញកំណើនភ្ញៀវទេសចរដែលនិយមតំបន់ទេសចរណ៍បែបព្រៃភ្នំ។

### ២.៤ ខេត្តមណ្ឌលគិរី

ខេត្តមណ្ឌលគិរីមានផ្ទៃដី ១៤ ២៨៨ គីឡូម៉ែត្រការ៉េ និងចែកជា ៤ ស្រុក (ស្រុកកែវសីមា ស្រុកកោះញែក ស្រុកពេជ្រាដា និងស្រុកអូររាំង) និង ក្រុងចំនួន ១ (ក្រុងសែនមនោរម្យ)។ ប្រជាជនសរុបក្នុងខេត្តមានចំនួន ១០០ ២៣៧ នាក់ (ឆ្នាំ ២០២៣) ជាមួយនឹងដង់ស៊ីតេប្រជាជន ៧ នាក់/គីឡូម៉ែត្រការ៉េ។ សេដ្ឋកិច្ចនៃខេត្តមណ្ឌលគិរី ពឹងអាស្រ័យលើវិស័យធំៗចំនួន ២ គឺ វិស័យកសិកម្ម និងវិស័យទេសចរណ៍ ដោយសារតែកត្តាដីមានជីជាតិ និងភាពអំណោយផលនៃសម្បត្តិធម្មជាតិ (ធាតុ-អាកាសត្រជាក់ ខ្យល់បរិសុទ្ធ វាលស្មៅបៃតង និងទេសភាពព្រៃភ្នំស្អាតៗ)។ ចំពោះវិស័យកសិកម្ម ក្នុងឆ្នាំ ២០២៣ ខេត្តមណ្ឌលគិរីមានផ្ទៃដីដាំដុះសរុបចំនួន ១២៨ ២៣៩ ហិកតា ដែលក្នុងនោះកសិផលចម្បងៗ មានដូចជា៖ ដំឡូងមី (៣២០ ៩៤២ តោន) ស្រូវ (១០៦ ៩៦៥ តោន) កៅស៊ូ (២៥ ៦៤៣ តោន) ស្វាយចន្ទី (៩ ៦២២ តោន) និងសណ្តែកបាយ (៥ ៥២៨ តោន)។ ទន្ទឹមនេះ, ខេត្តមណ្ឌលគិរី ក៏មានលក្ខណៈពិសេសដោយឡែកខុសប្លែកពីតំបន់ដទៃ ដែលមានភាពអំណោយផលដល់ការដាំដុះផលិតផលកសិកម្មផ្សេងទៀត ជាពិសេស ផ្កា បន្លែ និងផ្លែឈើ ដូចមានចង្អុលបង្ហាញក្នុងចក្ខុវិស័យនៃផែនការមេអភិវឌ្ឍន៍វិស័យទេសចរណ៍ ខេត្តមណ្ឌលគិរី ២០២១-២០៣៥។ ចំពោះវិស័យទេស-ចរណ៍វិញ ខេត្តមណ្ឌលគិរីសម្បូរទៅដោយ តំបន់ទេសចរណ៍ធម្មជាតិបែបទឹកជ្រោះ និងព្រៃភ្នំ ដូចជា ទឹកជ្រោះប៊ូស្រា ទឹកជ្រោះជ្រៃធំ ទឹកជ្រោះរមនា ទឹកជ្រោះមនោរម្យ ដែនជម្រកសត្វព្រៃភ្នំណាមលៀរ និងភ្នំដោះក្រមុំ ជាដើម។ ក្នុងឆ្នាំ ២០២៣, ខេត្តមណ្ឌលគិរី ទទួលភ្ញៀវទេសចរចំនួនប្រមាណ ២៦៦ ៤២២ នាក់ ក្នុងនោះភ្ញៀវទេសចរជាតិមានចំនួន ២៦១ ៤៩៤ នាក់ និងភ្ញៀវទេសចរអន្តរជាតិមានចំនួនប្រមាណ ៤ ៩២៨ នាក់។ ជារួម, ខេត្តនេះ មានសក្តានុពលខ្លាំងលើវិស័យកសិកម្ម និងទេសចរណ៍ ដោយសារកត្តាទាយជ្ជទានធម្មជាតិអំណោយផល និងចំនួនអាជីវកម្មទេសចរណ៍ដែលមានលទ្ធភាពពង្រីកបន្ថែមដើម្បីទទួលកំណើនភ្ញៀវទេសចរ។

## ៣. សក្តានុពល និងបញ្ហាប្រឈមចម្បងៗ

### ៣.១ សក្តានុពល

តំបន់ភូមិភាគឦសាន មានលក្ខណៈពិសេសដែលអំណោយផលខ្ពស់ដល់វិស័យកសិកម្ម កសិ-ឧស្សាហកម្ម និងទេសចរណ៍ ជាពិសេសទេសចរណ៍ធម្មជាតិ និងទេសចរណ៍អត្តសញ្ញាណពិសេស (Unique Identity Tourism)។ ទេសចរណ៍អត្តសញ្ញាណពិសេស គឺចង់សំដៅលើផលិតផលទេសចរណ៍វប្បធម៌, ធម្មជាតិ និងប្រវត្តិសាស្ត្រ ដែលមានលក្ខណៈពិសេសដោយឡែកសម្រាប់តែខេត្ត

និងតំបន់ភូមិភាគឦសាន, និង/ឬ ដែលមានតែនៅក្នុងប្រទេសកម្ពុជា នៅលើពិភពលោក ដើម្បីបង្កើតភាពទាក់ទាញខុសប្លែកពីខេត្តដទៃផ្សេងទៀត ដែលសម្បូរទៅដោយសម្បត្តិវប្បធម៌, ធម្មជាតិ និងប្រវត្តិ-សាស្ត្រដែរ។ ចំពោះវិស័យកសិកម្ម ដំណាំដែលជាសក្តានុពលក្នុងខេត្តទាំងបួន រួមមានជាអាទិ៍ កៅស៊ូ ស្វាយចន្ទី ដំឡូងមី ចេកអំបូងលឿង បន្លែ ផ្លែឈើ និងផ្កា។ ការចិញ្ចឹមសត្វជាលក្ខណៈពាណិជ្ជកម្មនៅទីវាល ក៏អាចជាសក្តានុពលបន្ថែមក្នុងវិស័យកសិកម្មផងដែរ។ ជាសរុបក្នុងខេត្តទាំងបួន, ក្នុងឆ្នាំ ២០២៣ បើធៀបនឹងទិន្នផលសរុបតាមប្រភេទដំណាំនីមួយៗទូទាំងប្រទេស, បរិមាណផលកៅស៊ូ (១៧៤ ១៩៩ តោន) ស្មើនឹង ៤៤,៤៦% បរិមាណផលស្វាយចន្ទី (១៨៥ ២២១ តោន) ស្មើនឹង ៣៧,៤២% បរិមាណផលដំឡូងមី (២ ៨៧៥ ៤៩៨ តោន) ស្មើនឹង ២០,២៧% និងបរិមាណផលចេកអំបូងលឿង (២៥៨ ៨៧៤ តោន) ស្មើនឹង ៧៧,១០%។

| ទិន្នន័យវិស័យកសិកម្ម ឆ្នាំ ២០២៣ | | | | | | |
|---|---|---|---|---|---|---|
| | **ក្រចេះ** | **ស្ទឹងត្រែង** | **រតនគិរី** | **មណ្ឌលគិរី** | **សរុប** | **ធៀបនឹងទូទាំងប្រទេស** |
| **ផ្ទៃដីដាំដុះសរុប (ហិកតា)** | ១៧០ ៦២៨ | ១៥០ ៣៦៧ | ១១៨ ៨២៧ | ១២៨ ២៣៩ | ៥៦៨ ០៦១ | ១០,៣១ % |
| **បរិមាណផលិតកម្មសរុប (តោន)** | | | | | | |
| **កៅស៊ូ** | ៧៥ ៦៥៤ | ៧ ៤៤២ | ៦៥ ៤៦០ | ២៥ ៦៤៣ | ១៧៤ ១៩៩ | ៤៤,៤៦ % |
| **ស្វាយចន្ទី** | ៩៣ ០៣០ | ៤៧ ៣៨៨ | ៣៥ ១៨១ | ៩ ៦២២ | ១៨៥ ២២១ | ៣៧,៤២ % |
| **ដំឡូងមី** | ១ ៥២៩ ៦៩១ | ៥៩៩ ០៩៧ | ៤២៥ ៧៦៨ | ៣២០ ៩៤២ | ២ ៨៧៥ ៤៩៨ | ២០,២៧ % |
| **ចេកអំបូងលឿង** | ៤៩ ១២០ | ៤៨ ០០០ | ១៦១ ៧៥៤ | - | ២៥៨ ៨៧៤ | ៧៧,១០ % |

*ប្រភពទិន្នន័យ៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងខេត្តទាំងបួន*

ទន្ទឹមគ្នានេះ, ខេត្តទាំងបួននៅភូមិភាគឦសាននេះក៏សម្បូរទៅដោយតំបន់ទេសចរណ៍ និងចំណុចទាក់ទាញទេសចរណ៍ (attractions) ប្លែកៗ ដូចជា ផ្សោតទឹកសាប សត្វទោចថ្ពាល់លឿង ស្វាកន្ទុយស សត្វត្មាត តំបន់រ៉ាមសារ វប្បធម៌ជនជាតិដើមភាគតិច និងតំបន់ស្លាកស្នាមប្រវត្តិសាស្ត្រ ដែលចំណុចទាក់ទាញទាំងនេះ អាចត្រូវបានប្រើប្រាស់ក្នុងការអភិវឌ្ឍវិស័យទេសចរណ៍អត្តសញ្ញាណពិសេស (Unique Identity Tourism)។ ជាតួលេខ, ចំនួនភ្ញៀវទេសចរ ទាំងភ្ញៀវជាតិ និងអន្តរជាតិ ដែលបានទៅកម្សាន្តក្នុងខេត្តទាំងបួននេះ ក្នុងឆ្នាំ ២០២៣ មានចំនួន ៨៤២ ៩១៥ នាក់ ឬប្រមាណ ៣% នៃភ្ញៀវទេសចរសរុបទូទាំងប្រទេស។

### ៣.២ បញ្ហាប្រឈមចម្បងៗ

បើទោះបីតំបន់ភូមិភាគឦសានមានសក្តានុពលខ្ពស់ ជាពិសេសខាងវិស័យកសិកម្ម កសិ-ឧស្សាហកម្ម និងទេសចរណ៍យ៉ាងណាក្តី ក៏ខេត្តនីមួយៗហាក់មិនទាន់អាចទាញយកនូវផលប្រយោជន៍ពីសក្តានុពល និងកត្តាទាយជ្ជទានទាំងនេះឱ្យបានជាអតិបរមានៅឡើយ។ ជាក់ស្តែង, គិតត្រឹមបច្ចុប្បន្ន

ផលិតកម្មកែច្នៃផលិតផលកសិ-ឧស្សាហកម្មនៅតំបន់នេះ គឺនៅមានកម្រិត និងក្នុងទ្រង់ទ្រាយតូច (small scale) ហើយមានលក្ខណៈរាយប៉ាយ។ កសិផលសំខាន់ៗ ជាពិសេស កៅស៊ូ ស្វាយចន្ទី ដំឡូងមី និងចេកអំបូងលឿង ដែលសុទ្ធសឹងជាដំណាំសក្តានុពលក្នុងបណ្តាខេត្តទាំងនេះ ស្ទើរតែទាំងអស់គឺត្រូវបាននាំចេញជាវត្ថុធាតុដើម (raw materials) ទៅប្រទេសជិតខាង ដែលធ្វើឱ្យបាត់បង់តម្លៃបន្ថែមក្នុងសេដ្ឋកិច្ច។ ក្រៅពីវិស័យកសិកម្ម និងកសិ-ឧស្សាហកម្ម, តំបន់ទាំងនេះក៏មានលក្ខខណ្ឌអំណោយផលខ្ពស់លើវិស័យទេសចរណ៍ ប៉ុន្តែការវិនិយោគ (ផ្នែកផ្គត់ផ្គង់) និងទំហំភ្ញៀវទេសចរ (ផ្នែកតម្រូវការ) ទៅទស្សនានៅបណ្តាខេត្តទាំងនេះ គឺនៅមានកម្រិតទាប។

ការមិនទាន់អាចទាញយកប្រយោជន៍ពីកត្តាទាយជ្ជទានទាំងនេះ ឧទា. ឧបសគ្គក្នុងការទាក់ទាញវិនិយោគិន និងភ្ញៀវទេសចរ បណ្តាលមកពីបញ្ហាប្រឈមចម្បងៗ មួយចំនួន៖ ថ្លៃអគ្គិសនីមិនមានភាពប្រកួតប្រជែង, អត្រាការប្រាក់ខ្ពស់, កង្វះហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់សំខាន់ៗ កង្វះកម្លាំងពលកម្មទាំងជំនាញ, បរិមាណ និងគុណភាព,បញ្ហាការចុះបញ្ជីដីធ្លី, បញ្ហាសម្បទានដីសេដ្ឋកិច្ចអសកម្ម, បញ្ហានៃការគ្រប់គ្រងរបស់សហគមន៍ទេសចរណ៍ និងកង្វះការចូលរួមពីវិស័យឯកជន។

## ៤. គោលគំនិត "៣.៣.៣" នៃការរៀបចំកម្មវិធីពិសេស

ជាលក្ខណៈគោលគំនិត, កម្មវិធីពិសេសមានលក្ខណៈសម្គាល់ «៣.៣.៣» ពោលគឺ **ទស្សនាទាន ៣, វិស័យអាទិភាព ៣** និង **វិធានការគាំទ្រ និងជំរុញការវិនិយោគ ៣ ប្រភេទ**។

### ៤.១ ទស្សនាទាន ៣

**ទី១.** កែប្រែមុខមាត់ខេត្តទាំងបួន ឱ្យទៅជាខេត្តដែលមានមូលដ្ឋានសេដ្ឋកិច្ចពឹងផ្អែកលើកសិកម្ម, កសិ-ឧស្សាហកម្ម, និងទេសចរណ៍ យោងលើកត្តាទាយជ្ជទានរបស់ខេត្តនីមួយៗ និងដោយមានភាពប្រទាក់ក្រឡាជាមួយនឹងគោលនយោបាយជាតិផ្សេងៗ,

**ទី២.** ដោះស្រាយបញ្ហាប្រឈមជាក់ស្តែងដែលនាំមកនូវលទ្ធផលឆាប់រហ័ស (Low-hanging and intermediate measures) ជាពិសេសកត្តាជំរុញការទាក់ទាញវិនិយោគឯកជន និង;

**ទី៣.** ជំរុញសហថាមពលដែលកើតចេញពីការប្រមូលផ្តុំ (Clustering Effects) ដើម្បីឈានទៅអភិវឌ្ឍសេដ្ឋកិច្ចមាត្រដ្ឋាន (Economies of Scale) ជាជាងការវិនិយោគដែលមានលក្ខណៈរាយប៉ាយ និងមិនអាចផ្សារភ្ជាប់គ្នាបាន។

### ៤.២ វិស័យអាទិភាព ៣

**ទី១.** កសិកម្ម៖ ផ្តោតលើការដាំដុះដំណាំកសិកម្មសំខាន់ៗ ដែលមានសក្តានុពលសេដ្ឋកិច្ចបូករួមទាំង ផ្កា បន្លែ ផ្លែឈើ និងឈើដាំ និងការចិញ្ចឹមសត្វជាលក្ខណៈពាណិជ្ជកម្មនៅទីវាល;

**ទី២.** កសិ-ឧស្សាហកម្ម៖ ផ្តោតលើការកែច្នៃ និង/ឬ វេចខ្ចប់ (processing and/or packaging) នៃផលិតផលគន្លឹះ ជាអាទិ៍ កៅស៊ូ ស្វាយចន្ទី ដំឡូងមី ចេកអំបូង-លឿង ផ្លែឈើ និងឈើដាំ និង;

**ទី៣.** ទេសចរណ៍៖ ផ្តោតលើទេសចរណ៍អត្តសញ្ញាណពិសេស (Unique Identity Tourism) ដែលសំដៅលើការខិតខំអភិវឌ្ឍផលិតផលទេសចរណ៍វប្បធម៌ ធម្មជាតិ និងប្រវត្តិ-សាស្ត្រ ដែលមានលក្ខណៈពិសេសដោយឡែកសម្រាប់តែខេត្ត និងតំបន់ភូមិភាគ-ឦសាន, និង/ឬ ដែលមានតែនៅក្នុងប្រទេសកម្ពុជា នៅលើពិភពលោក ដើម្បីបង្កើតភាពទាក់ទាញខុសប្លែកពីខេត្តដទៃផ្សេងទៀត ដែលសម្បូរទៅដោយសម្បត្តិវប្បធម៌, ធម្មជាតិ និងប្រវត្តិសាស្ត្រដែរ។ ឧទាហរណ៍ដូចជា៖ អន្លង់ផ្សោតទឹកសាប នៅខេត្ត-ក្រចេះ និងស្ទឹងត្រែង, សត្វទោចថ្ពាល់លឿង (southern yellow-cheeked crested gibbons) និង ស្វាកន្ទុយស (black-shanked douc langurs) នៅដែនជម្រកសត្វព្រៃកែវសីមា ខេត្តមណ្ឌលគិរី និងក្នុងឧទ្យានជាតិវីរៈជ័យ ក្នុងខេត្តរតនគិរី, តំបន់រ៉ាមសារ នៅខេត្តស្ទឹងត្រែង, សត្វត្មាតនៅដែនជម្រកសត្វព្រៃសៀមប៉ាង ក្នុងខេត្ត-ស្ទឹងត្រែង, វប្បធម៌ និងជីវភាពរស់នៅរបស់ជនជាតិដើមភាគតិច, ជ្រោះសុគមិត្រ និងតំបន់ស្លាកស្នាមប្រវត្តិសាស្ត្រ (តំបន់ប្រើប្រាស់ច្រើនយ៉ាងសសរស្តម្ភសត្វតោ) ជាដើម។ ជាមួយគ្នានេះ, វិស័យអាទិភាពនេះក៏ផ្តោតលើសកម្មភាពមួយចំនួនដូចជា ការបង្កើតតំបន់អេកូទេសចរណ៍, ការបង្កើតតំបន់ទេសចរណ៍ពិសិដ្ឋ, ការបង្កើតសួនរុក្ខជាតិ (សួនបូតានិក) ឬសួនទេសចរណ៍ ឬសួនសត្វ ឬសកម្មភាពអភិរក្សជីវៈចម្រុះ និងធនធានសេនេទិក, និងការបង្កើតរមណីយដ្ឋានដែលមានសេវាកម្មចម្រុះ (រួមមានជាអាទិ៍ សេវាកម្ម ដូចជាសណ្ឋាគារ សួនកម្សាន្ត កន្លែងហាត់កីឡា និងសួនសត្វ)។

### ៤.៣ វិធានការគាំទ្រ និងជំរុញការវិនិយោគ ៣ ប្រភេទ

**ទី១.** វិធានការផ្នែកពន្ធដារ និងពន្ធគយ;

**ទី២.** ការផ្តល់ហិរញ្ញប្បទានក្រោមអត្រាការប្រាក់សមរម្យ និង;

**ទី៣.** ការជួយកាត់បន្ថយថ្លៃដើមផលិតកម្ម,ការសម្រួលនីតិវិធី និងការគាំទ្រសកម្មភាពវិនិ-យោគឯកជន។

## ៥. វិធានការ និងលក្ខខណ្ឌវិនិច្ឆ័យទទួលបានការគាំទ្រ និងជំរុញការវិនិយោគ

វិធានការគាំទ្រ និងជំរុញការវិនិយោគនេះ នឹងត្រូវបានអនុវត្តចំពោះ គម្រោងវិនិយោគ ឬសកម្មភាពធុរកិច្ច ដែលបានចុះបញ្ជីជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (គ.ល.គ.), គម្រោងពង្រីកនៃ គ.ល.គ. ដែលមានស្រាប់, គម្រោងវិនិយោគ ឬសកម្មភាពធុរកិច្ចរបស់សហគមន៍កសិកម្មទំនើប និង គម្រោងវិនិយោគ ឬសកម្មភាពធុរកិច្ចរបស់សហគមន៍ទេសចរណ៍ ដែលត្រូវចាប់ផ្តើម

ដំណើរការ នៅក្នុងឆ្នាំ ២០២៥ ដល់ ២០២៨ នៅក្នុងខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តរតនគិរី ឬខេត្ត-មណ្ឌលគិរី។ ជាមួយគ្នានេះ, ក្នុងគោលដៅជំរុញសកម្មភាពវិនិយោគ ជាពិសេសកៀរគរមូលធនវិនិយោគក្នុងស្រុក ដើម្បីទាញយកឧត្តមប្រយោជន៍ឱ្យបានជាអតិបរមា, រាជរដ្ឋាភិបាលនឹងរៀបចំលិខិតបទដ្ឋានគតិយុត្តកំណត់លក្ខខណ្ឌបន្ធូរបន្ថយពិសេសដាច់ដោយឡែក សំដៅបើកផ្លូវឱ្យសកម្មភាពធុរ-កិច្ចទូទៅ (ដែលមិនមែនជា គ.ល.គ.) អាចស្នើសុំជា គ.ល.គ. ដើម្បីធ្វើការវិនិយោគនៅភូមិភាគឦសានក្នុងឆ្នាំ ២០២៥-២០២៨ ជាមួយនឹងការទទួលបាននូវការលើកទឹកចិត្តដូច គ.ល.គ.។

វិធាននៃការផ្ដល់ការលើកទឹកចិត្តចំពោះ គ.ល.គ. ពាក់ព័ន្ធទៅនឹងផលិតកម្ម និងការកែច្នៃកសិផល ដែលមានលក្ខណៈជាយុទ្ធសាស្ត្រ ត្រូវតែមានសង្គតិភាព និងសម្របជាមួយនឹងក្របខណ្ឌនៃយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ក្នុងការគ្រប់គ្រង និងអភិវឌ្ឍលើមុខទំនិញយុទ្ធសាស្ត្រសំខាន់ៗ។

**១ វិធានការផ្នែកពន្ធដារ និងពន្ធគយ**

**ក- <u>គម្រោងវិនិយោគ ឬសកម្មភាពធុរកិច្ចជា គ.ល.គ. ក្នុងវិស័យទូទៅ ក្រៅពីវិស័យអាទិភាព នឹងទទួលបានការលើកទឹកចិត្តវិនិយោគ ដូចខាងក្រោម៖</u>**

- លើកលែងពន្ធលើប្រាក់ចំណូល ប្រាក់រំដោះពន្ធលើប្រាក់ចំណូល និងពន្ធអប្បបរមា រយៈពេល ៣ ឆ្នាំបន្ថែម ដោយរយៈពេលលើកលែងពន្ធត្រូវគិតចាប់ពីពេល ដែលគម្រោងមានចំណូលពីសកម្មភាពអាជីវកម្មដំបូង;
- អនុញ្ញាតឱ្យអនុវត្តអាករលើតម្លៃបន្ថែមអត្រាសូន្យភាគរយចំពោះការទិញធាតុចូលផលិត-កម្ម ដែលផលិតក្នុងស្រុក;
- លើកលែងពន្ធកាត់ទុកលើការជួលអចលនទ្រព្យ ពន្ធលើផ្ទាំងផ្សព្វផ្សាយ និងពន្ធប៉ាតង់ រយៈពេល ៣ ឆ្នាំ និង;
- លើកលែងពន្ធលើប្រាក់បៀវត្សសម្រាប់កម្មករនិយោជិត ដែលទទួលបានប្រាក់បៀវត្សប្រចាំខែ ក្រោម ២ ០០០ ០០១ រៀល និងបម្រើការងារសម្រាប់ គ.ល.គ. ក្នុងខេត្តទាំងបួននៅភូមិភាគឦសាន។

**ខ- <u>គម្រោងវិនិយោគ ឬសកម្មភាពធុរកិច្ច ក្នុងវិស័យអាទិភាព៖</u>**

គ.ល.គ. ឬគម្រោងវិនិយោគ ឬសកម្មភាពធុរកិច្ច របស់សហគមន៍កសិកម្មទំនើប ក្នុងវិស័យកសិកម្ម និង គ.ល.គ. ក្នុងវិស័យកសិ-ឧស្សាហកម្ម ស្របតាមអាទិភាពដែលបានកំណត់ ព្រមទាំង គ.ល.គ. ឬគម្រោងវិនិយោគ ឬសកម្មភាពធុរកិច្ចរបស់សហគមន៍ទេសចរណ៍ ក្នុងវិស័យទេសចរណ៍ រួមមាន ការបង្កើតតំបន់ទេសចរណ៍អត្តសញ្ញាណពិសេស, ការបង្កើតតំបន់អេកូទេសចរណ៍, ការបង្កើតតំបន់ទេសចរណ៍ពិសិដ្ឋ, ការបង្កើតសួនភូតគាម (សួនបុប្ផានិក) ឬសួនទេសចរណ៍ ឬសួនសត្វ ឬសកម្មភាពអភិរក្សជីវៈចម្រុះនិងការបង្កើតរមណីយដ្ឋានដែលមានសេវាកម្មចម្រុះ (រួមមានជាអាទិ៍សេវាកម្មដូចជា សណ្ឋាគារ សួនកម្សាន្ត កន្លែងហាត់កីឡា និងសួនសត្វ) នឹងទទួលបានការលើកទឹកចិត្តវិនិយោគ ដូចខាងក្រោម៖

- លើកលែងពន្ធលើប្រាក់ចំណូល ប្រាក់រំដោះពន្ធលើប្រាក់ចំណូល និងពន្ធអប្បបរមា រយៈពេល ១២ ឆ្នាំ ដោយរយៈពេលលើកលែងពន្ធត្រូវគិតចាប់ពីឆ្នាំដែលគម្រោងវិនិយោគ ឬសកម្មភាពធុរកិច្ចមានចំណូលពីសកម្មភាពអាជីវកម្មដំបូង;
- ចំពោះ គ.ល.គ. ឬ គម្រោងវិនិយោគឬសកម្មភាពធុរកិច្ចរបស់សហគមន៍កសិកម្មទំនើប ក្នុងវិស័យកសិកម្ម និងកសិ-ឧស្សាហកម្ម, ផ្តល់ការលើកទឹកចិត្តពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែម ជាបន្ទុករបស់រដ្ឋលើការនាំចូលសម្ភារៈសាងសង់ បរិក្ខារសំណង់ សម្ភារៈបរិក្ខារផលិតកម្ម និងធាតុចូលផលិតកម្ម;
- ចំពោះ គ.ល.គ. ឬគម្រោងវិនិយោគ ឬសកម្មភាពធុរកិច្ចរបស់សហគមន៍ទេសចរណ៍ ក្នុងវិស័យទេសចរណ៍, ផ្តល់ការលើកទឹកចិត្តពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែម ជាបន្ទុករបស់រដ្ឋលើការនាំចូលសម្ភារៈសាងសង់ បរិក្ខារសំណង់ និងសម្ភារៈ-បរិក្ខារផលិតកម្ម;
- អនុញ្ញាតឱ្យអនុវត្តអាករលើតម្លៃបន្ថែមអត្រាសូន្យភាគរយចំពោះការទិញធាតុចូលផលិត-កម្ម ដែលផលិតក្នុងស្រុក;
- លើកលែងពន្ធកាត់ទុកលើការជួលអចលនទ្រព្យ ពន្ធលើផ្ទាំងផ្សព្វផ្សាយ និងពន្ធប៉ាតង់ រយៈពេល ៣ ឆ្នាំ និង;
- លើកលែងពន្ធលើប្រាក់បៀវត្សសម្រាប់កម្មករនិយោជិត ដែលទទួលបានប្រាក់បៀវត្ស ប្រចាំខែ ក្រោម ២ ០០០ ០០១ រៀល និងបម្រើការងារសម្រាប់ គ.ល.គ. ក្នុងខេត្តទាំងបួន នៅភូមិភាគឦសាន។

គ-**<u>គម្រោងពង្រីកនៃ គ.ល.គ. ក្នុងឆ្នាំ ២០២៥-២០២៨ នឹងទទួលបានការលើកទឹកចិត្ត វិនិយោគ ដូចខាងក្រោម៖</u>**

- លើកលែងពន្ធលើប្រាក់ចំណូល ប្រាក់រំដោះពន្ធលើប្រាក់ចំណូល និងពន្ធអប្បបរមា រយៈពេល ៣ ឆ្នាំបន្ថែម ពីលើរយៈពេលជាក់លាក់ណាមួយ ទៅតាមប្រភេទក្រុមសកម្មភាព វិនិយោគដើម ផ្អែកតាមសមាមាត្រនៃអត្រាទុនពង្រីក ស្របតាមអនុក្រឹត្យស្តីពីការអនុវត្ត ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា;
- អនុញ្ញាតឱ្យអនុវត្តអាករលើតម្លៃបន្ថែមអត្រាសូន្យភាគរយចំពោះការទិញធាតុចូលផលិត-កម្ម ដែលផលិតក្នុងស្រុក;
- លើកលែងពន្ធកាត់ទុកលើការជួលអចលនទ្រព្យ ពន្ធលើផ្ទាំងផ្សព្វផ្សាយ និងពន្ធប៉ាតង់ រយៈពេល ៣ ឆ្នាំ និង;
- លើកលែងពន្ធលើប្រាក់បៀវត្សសម្រាប់កម្មករនិយោជិត ដែលទទួលបានប្រាក់បៀវត្ស ប្រចាំខែ ក្រោម ២ ០០០ ០០១ រៀល និងបម្រើការងារសម្រាប់ គ.ល.គ. ក្នុងខេត្តទាំងបួន នៅភូមិភាគឦសាន។

*<u>សម្គាល់</u>៖ និយមន័យ និងវិធីគណនាទុនពង្រីក ត្រូវអនុវត្តដូចគ្នាទៅនឹងវិធានដូចមានចែងក្នុងប្រកាសលេខ ៣១៣ សហវ.ប្រក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៤ ស្តីពីការលើកទឹកចិត្តពន្ធលើប្រាក់ចំណូលចំពោះគម្រោងពង្រីកនៃ គ.ល.គ.។*

**ឃ- <u>សកម្មភាពធុរកិច្ច ដែលមិនទាន់បានចុះបញ្ជីពន្ធដារ៖</u>**

សម្រាប់សកម្មភាពធុរកិច្ច ដែលកំពុងដំណើរការ តែមិនទាន់បានចុះបញ្ជីពន្ធដារ ត្រូវទៅចុះបញ្ជីពន្ធដារ តាមនីតិវិធីជាធរមានដោយស្ម័គ្រចិត្ត ក្នុងឆ្នាំ ២០២៥ នឹងទទួលបានការលើកលែង ពិន័យទោសទណ្ឌ បំណុលពន្ធ (រួមមាន ប្រាក់ពន្ធ ពន្ធបន្ថែម និងការប្រាក់) និងការផាកពិន័យជាប្រាក់ចំពោះការមិនបានបំពេញអនុលោមភាពកន្លងមកមុនការចុះបញ្ជីពន្ធដារដោយស្ម័គ្រចិត្ត ដែលអនុលោមតាមយុទ្ធសាស្ត្រជាតិ ស្តីពី ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឆ្នាំ ២០២៣-២០២៨។

ទន្ទឹមនេះ, ដើម្បីទទួលបានការលើកទឹកចិត្តបន្ថែម ដូចមានក្នុងវិធានការផ្នែកពន្ធដារ និងពន្ធគយ, សកម្មភាពធុរកិច្ច ដែលបានចុះបញ្ជីពន្ធដារដោយស្ម័គ្រចិត្ត ត្រូវចុះបញ្ជីជា គ.ល.គ. ក្នុងឆ្នាំ ២០២៥ ស្របតាមលិខិតបទដ្ឋានគតិយុត្តកំណត់លក្ខខណ្ឌបន្ធូរបន្ថយនៃការចុះបញ្ជីជា គ.ល.គ. ក្នុងខេត្តទាំងបួននៅភូមិភាគឦសាន នៃកម្មវិធីពិសេសនេះ។

**ង- <u>គម្រោងវិនិយោគ ឬសកម្មភាពធុរកិច្ច ដែលមិនទទួលបានការលើកទឹកចិត្ត</u>**

ចំពោះគម្រោងវិនិយោគធំៗ, គម្រោងវិនិយោគ និងសកម្មភាពធុរកិច្ច ដែលមានវេទយិតភាព រួមបញ្ចូលគម្រោងដែលមានទីតាំងនៅក្បែរព្រំដែន ត្រូវអនុវត្តដោយនីតិវិធីដោយឡែក។ ចំពោះគម្រោងវិនិយោគ និងសកម្មភាពធុរកិច្ចផ្សេងទៀត ដែលស្ថិតនៅក្រៅវិសាលភាពនៃកម្មវិធីពិសេសនេះ ត្រូវដំណើរការតាមយន្តការរបស់រាជរដ្ឋាភិបាល ស្របតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងនីតិវិធីជាធរមាន។ ជាមួយគ្នានេះ, ការលើកទឹកចិត្តផ្នែកពន្ធ (ពន្ធដារ និងពន្ធគយ) ក្រោមកម្មវិធីពិសេសនេះ មិនត្រូវអនុវត្ត ចំពោះសកម្មភាពវិនិយោគ និងធុរកិច្ចក្នុងវិស័យ ដូចខាងក្រោម៖

- ល្បែងពាណិជ្ជកម្ម;
- សេវាកម្ម និងអាជីវកម្មរូបិយវត្ថុ និងហិរញ្ញវត្ថុ រួមមានធនាគារ ស្ថាប័នហិរញ្ញវត្ថុ ក្រុមហ៊ុនធានារ៉ាប់រង និងប្រតិបត្តិការហិរញ្ញវត្ថុអន្តរការិយកម្មគ្រប់ប្រភេទ;
- កម្មន្តសាលភេសជ្ជៈ (វៀរលែងតែកម្មន្តសាលភេសជ្ជៈ ធ្វើពីផលិតផលកសិកម្ម);
- ការសិក្សាស្រាវជ្រាវប្រេងកាត និងរ៉ែគ្រប់ប្រភេទ;
- ប្រតិបត្តិការ និងអាជីវកម្មធនធានរ៉ែ;
- សកម្មភាពលក់ដុំ និងលក់រាយទំនិញ ថ្នាំជក់ ភេសជ្ជៈ គ្រឿងស្រវឹង យានយន្តគ្រប់ប្រភេទ ប្រេងឥន្ធនៈ និងឧស្ម័ន រួមទាំងសកម្មភាពជួសជុលយានយន្ត និងទោចក្រយានយន្តគ្រប់ប្រភេទ;
- សកម្មភាពវិនិយោគលើសេវាកម្មខារ៉ាអូខេ រង្គសាល បានីយដ្ឋាន កន្លែងម៉ាស្សា អាហារដ្ឋាន កន្លែងហាត់ប្រាណ គូបជួល ផ្សារលក់ដុំលក់រាយ សេវាបញ្ញើ;
- សកម្មភាពផ្តត់ផ្គង់អគ្គិសនីរបស់សេវាករអគ្គិសនី និង;

- សកម្មភាពសេវាកម្មស្ថាបត្យកម្ម សេវាកម្មវិស្វកម្ម និងលទ្ធកម្មសាធារណៈ។

## ២ ការផ្ដល់ហិរញ្ញប្បទានក្រោមអត្រាការប្រាក់សមរម្យ

ការដាក់ចេញនូវកម្មវិធីហិរញ្ញប្បទានក្រោមអត្រាការប្រាក់សមរម្យ ដោយផ្ដោតជាពិសេសលើសហគ្រាសធុនតូច និងមធ្យម, សហគមន៍កសិកម្មទំនើប និងសហគមន៍ទេសចរណ៍ តាមរយៈធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ARDB) និងធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា (SME Bank) ដើម្បីផ្ដល់ឥណទាន ក្នុងវិស័យកសិកម្ម កសិ-ឧស្សាហកម្ម និងទេសចរណ៍ ស្របតាមអាទិភាព ដែលបានកំណត់ខាងលើក្នុងគោលដៅ ១. គាំទ្រដល់ដំណើរការវិនិយោគ ឬពង្រីកអាជីវកម្ម, ២. ប្រមូលទិញ ឬស្តុកទុកកសិផល និង ៣. ជំរុញអាជីវកម្មកែច្នៃ និង/ឬ វេចខ្ចប់។

## ៣ ការជួយកាត់បន្ថយថ្លៃដើមផលិតកម្ម, ការសម្រួលនីតិវិធី និងការគាំទ្រសកម្មភាពវិនិយោគឯកជន

ការដាក់ចេញនូវវិធានការដែលមានចរិតអន្តរស្ថាប័ន និងប្រទាក់ក្រឡា ទាំងការលើកទឹកចិត្តជាបន្ទុករដ្ឋ និងការសម្រួលនីតិវិធីរដ្ឋបាលនានា សំដៅចូលរួមកាត់បន្ថយថ្លៃដើមផលិតកម្ម និងលើក-កម្ពស់ផលិតភាពផលិតកម្ម ដូចខាងក្រោម៖

- សម្រួលបែបបទ និងនីតិវិធីវិនិយោគ និងធុរកិច្ច រួមទាំង ការស្នើសុំអាជ្ញាបណ្ណ, វិញ្ញាបនបត្រ និងលិខិតអនុញ្ញាតនានា ព្រមទាំងការចុះបញ្ជីជា គ.ល.គ.;
- សម្រួលនីតិវិធី បែបបទ និងការអនុញ្ញាតផ្សេងៗ សម្រាប់បម្រើដល់ការអនុវត្តគម្រោង ឬសកម្មភាពពង្រីកការវិនិយោគ និង/ឬ ធុរកិច្ច;
- ពង្រឹងយន្តការ ឬនីតិវិធីដោះស្រាយបញ្ហាប្រឈមជាក់ស្តែង ដែលជាបន្ទុកបន្ថែមរបស់វិនិ-យោគិនក្នុងការចុះបញ្ជី និងដំណើរការអាជីវកម្ម;
- ផ្ដល់ជូនការអនុគ្រោះថ្លៃប្រើប្រាស់អគ្គិសនីដូចមានក្នុងវិស័យកសិកម្ម សម្រាប់វិស័យកសិ-ឧស្សាហកម្ម រួមមានការកែច្នៃ និង/ឬ ការវេចខ្ចប់ នៃផលិតផលគន្លឹះ ជាអាទិ៍ កៅស៊ូ ស្វាយចន្ទី ដំឡូងមី ចេកអំបូងលឿង ផ្លែឈើ និងឈើដាំ;
- លើកទឹកចិត្តការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគន្លឹះៗ ដើម្បីគាំទ្រដល់ការវិនិយោគឯកជនក្រោមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ដែលមានដូចជា គម្រោងកំពង់ផែ, គម្រោងសួនកសិ-ឧស្សាហកម្ម, គម្រោងបូមស្ពានផ្លូវនាវាចរណ៍ និងគម្រោងអាកាសយានដ្ឋាន;
- ដាក់ចេញនូវយន្តការសម្របសម្រួលក្នុងការផ្ទេរគម្រោងសម្បទានដីសេដ្ឋកិច្ចអសកម្ម ឱ្យទៅអ្នកវិនិយោគិនដែលមានបំណងច្បាស់លាស់ និងដាក់លាក់ក្នុងការ វិនិយោគនិងពង្រីកសកម្មភាពធុរកិច្ច លើវិស័យអាទិភាពដែលបានកំណត់ក្នុងលក្ខខណ្ឌអនុគ្រោះខ្ពស់;
- អនុញ្ញាតឱ្យមានការបញ្ជាក់វិញ្ញាបនបត្រអនាម័យ និងភូតគាមអនាម័យ (Phytosanitary Certificate) ដោយអង្គភាពមានសមត្ថកិច្ចនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅខេត្តជាប់ព្រំដែនដែលមានច្រកអន្តរជាតិ;

- ពង្រឹងយន្តការផលិតកម្មកសិកម្មតាមកិច្ចសន្យា (Contract Farming) លើទំនិញកសិ-ឧស្សាហកម្មយុទ្ធសាស្ត្ររវាងអ្នកផលិត (ផ្ដល់អាទិភាពដល់សហគមន៍កសិកម្មទំនើប) និងក្រុមហ៊ុនកែច្នៃក្នុងស្រុក;
- ពន្លឿនការចុះបញ្ជីដីធ្លី ឬប័ណ្ណកម្មសិទ្ធដីធ្លីនៅតាមតំបន់ជាយក្រុង ឬទីប្រជុំជននៃបណ្ដាខេត្តនីមួយៗ និង;
- រៀបចំឱ្យមានវគ្គបណ្ដុះបណ្ដាលកិច្ចទីផ្សារឌីជីថល (Digital Marketing) និងដាក់ឱ្យអនុវត្តកម្មវិធីបរិវត្តកម្មឌីជីថលសហគ្រាស (Enterprises Go Digital-EGD) ដើម្បីជំរុញការចូលរួមរបស់សហគ្រាសធុនតូច និងមធ្យម និងបង្កើនលទ្ធភាពក្នុងការតភ្ជាប់ជាមួយទីផ្សារ។

## ៦. យន្តការអនុវត្ត, តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

ដើម្បីធានានូវប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ក្នុងការអនុវត្ត «**កម្មវិធីពិសេសជំរុញការវិនិយោគក្នុងខេត្តទាំងបួននៅភូមិភាគពាយ័ព្យ/ល្វាសាន នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០២៥-២០២៨**», យន្តការអនុវត្ត តាមដាន និងវាយតម្លៃ នៃកម្មវិធីពិសេសនេះ ត្រូវបានកំណត់ដូចខាងក្រោម៖

**ទី១. ក្រុមការងារជំរុញការវិនិយោគក្នុងភូមិភាគឦសាន (ក.វ.ឦសាន)**» ត្រូវបានបង្កើតក្រោមឆ័ត្រគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (គ.ស.ហ.) និងមានសិទ្ធិប្រើ-ប្រាស់ត្រាក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់បំពេញភារកិច្ច ទាំងតាមទម្រង់ច្បាប់ដើម និងតាមប្រព័ន្ធអេឡិចត្រូនិក។ ក្រុមការងារនេះ មានភារកិច្ចដឹកនាំ សម្របសម្រួល និងអនុវត្តកម្មវិធីពិសេសនេះ ដោយដើរតួនាទីជា "ច្រកចេញចូលតែមួយ" ដែលមានតួនាទីពិនិត្យ វាយតម្លៃ និងផ្ដល់ការ-អនុម័តគម្រោង, ផ្ដល់លិខិតអនុញ្ញាត ឬអាជ្ញាបណ្ណនានា ជាកញ្ចប់ទៅលើគម្រោងវិនិយោគ នៃកម្មវិធីពិសេសនេះ, ស្នើសុំដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្តចាំបាច់នានា តាមរយៈ គ.ស.ហ. និងអនុវត្តនូវកិច្ចការដទៃទៀត តាមការសម្រេចរបស់ គ.ស.ហ. ឬតាមការសម្រេចរបស់រាជរដ្ឋាភិបាល។ រាល់គម្រោងវិនិយោគ ដែលស្ថិតក្រោមវិសាលភាពនៃកម្មវិធីពិសេសនេះ ត្រូវដាក់ស្នើមកក្រុមការងារនេះ ដើម្បីក្រុមការងារពិនិត្យ វាយតម្លៃ និងផ្ដល់ការអនុម័ត។

**ទី២. ក.វ.ឦសាន** ត្រូវមានសមាសភាពមកពីក្រសួង និងស្ថាប័នពាក់ព័ន្ធ ដែលមានដូចជាក្រសួងមហាផ្ទៃ, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងអភិវឌ្ឍន៍ជនបទ, ក្រសួងពាណិជ្ជកម្ម, ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍, ក្រសួងរ៉ែ និងថាមពល, ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, ក្រសួងបរិស្ថាន, ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍, ក្រសួងសាធារណការ និងដឹកជញ្ជូន, ក្រសួងទេសចរណ៍, ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ, ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, អគ្គិសនីកម្ពុជា, ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា, ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម, និងរដ្ឋបាលខេត្តទាំងបួន (ខេត្ត

ក្រចេះ, ខេត្តស្ទឹងត្រែង, ខេត្តរតនគិរី និងខេត្តមណ្ឌលគិរី) ព្រមទាំងក្រសួង-ស្ថាប័នផ្សេងទៀត ដែលទទួលបានប្រតិភូកម្ម ឬមានសិទ្ធិសម្រេច ក្នុងនាមប្រធានក្រសួង-ស្ថាប័ន។

**ទី៣. គ.វ.៤សាន** មានលេខាធិការដ្ឋានមួយជាសេនាធិការ និងមានធនធានហិរញ្ញវត្ថុ ក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ លេខាធិការដ្ឋានដើរតួនាទីសម្របសម្រួលផ្នែករដ្ឋបាលទាំងអស់ និងមានការិយាល័យនៅរាជធានីភ្នំពេញ និងអាចបង្កើតការិយាល័យតាមបណ្ដាខេត្តនៅភូមិភាគ៤សាន តាមការចាំបាច់។

**ទី៤. គ.វ.៤សាន** ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈនូវកម្មវិធីពិសេសនេះ ឱ្យបានទូលំទូលាយ, ធ្វើការពន្យល់ឱ្យបានច្បាស់លាស់ និងត្រឹមត្រូវ, និងផ្ដល់សេវាបដិសណ្ឋារកិច្ច និងកិច្ចសហការល្អជាមួយវិនិយោគិន និងធុរជន ទាំងក្នុង និងក្រៅប្រទេស ដើម្បីលើកកម្ពស់ការយល់ដឹង និងទាក់ទាញការចូលរួមអនុវត្តពីកម្លាំងចលករសំខាន់ៗ។

**ទី៥. គ.វ.៤សាន** ត្រូវដាក់ចេញកម្មវិធីពង្រឹងសមត្ថភាពដល់ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញ ព្រមទាំង អ្នកពាក់ព័ន្ធ ដោយផ្ដោតលើការបំពេញភារកិច្ច, ការសម្របសម្រួល, ការផ្ដល់សេវាដល់វិនិយោគិន និងធុរជន, ការរៀបចំគម្រោង, និងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ដើម្បីផ្ដល់សេវា និងអនុវត្តការងារប្រកបដោយគណនេយ្យភាព តម្លាភាព និងប្រសិទ្ធភាព។

**ទី៦. គ.វ.៤សាន** ត្រូវធ្វើការតាមដាន និងវាយតម្លៃ ការអនុវត្តកម្មវិធីពិសេស តាមរយៈការរៀបចំកិច្ចប្រជុំក្រុមការងាររៀងរាល់ត្រីមាស ឬកិច្ចប្រជុំណាមួយតាមការចាំបាច់ ដើម្បីដោះស្រាយបញ្ហាប្រឈម, ដាក់ចេញវិធានការកែតម្រូវ, វាស់វែងពីការខិតខំប្រឹងប្រែង, និងវាយតម្លៃប្រសិទ្ធភាព និងលទ្ធផលនៃកម្មវិធីពិសេសនេះ។ ក្នុងគោលបំណងឆ្លើយតបនឹងកម្មវត្ថុនេះ, ក្របខណ្ឌអនុវត្តការងារនេះត្រូវរៀបចំតាមអភិក្រម "ជវភាពនៃប្រព័ន្ធតួអង្គតែមួយ" ដែលមានសហថាមពលព្រមគ្នា និងសង្គតិភាពជាមួយគ្នា, មានកិច្ចសម្របសម្រួលខ្ពស់ និងការទទួលខុសត្រូវ, មានកិច្ចសហការល្អ និងការចូលរួមពីក្រសួង-ស្ថាប័នពាក់ព័ន្ធ, និងមានការរៀបចំត្រួតពិនិត្យលទ្ធផលជាប្រចាំ។

**ទី៧. គ.វ.៤សាន** ត្រូវរៀបចំរបាយការណ៍វឌ្ឍនភាព និងការវាយតម្លៃការអនុវត្តកម្មវិធីពិសេសនេះ ប្រចាំឆ្នាំ ជូនរាជរដ្ឋាភិបាល តាមរយៈ គ.ស.ហ.។

## ៧. សេចក្ដីសន្និដ្ឋាន

ការដាក់ចេញនូវ **«កម្មវិធីពិសេសជំរុញការវិនិយោគក្នុងខេត្តទាំងបួននៅភូមិភាគ៤សាន នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០២៥-២០២៨»** គឺជាការបោះជំហានគោលនយោបាយដែលមានលក្ខណៈយុទ្ធសាស្ត្រ។ ពិតណាស់ថា កម្មវិធីពិសេសនេះចង់ជំរុញការអភិវឌ្ឍ នៃខេត្តទាំងបួន ដែលនៅឆ្ងាយពីមជ្ឈមណ្ឌលកំណើនសេដ្ឋកិច្ច ប៉ុន្តែទន្ទឹមនេះ, កម្មវិធីពិសេសនេះក៏ជាកាតាលីករជួយពង្រឹងឯករាជ្យភាពនៃកម្លាំងសេដ្ឋកិច្ច និងសមត្ថភាពជាប៉ូលសេដ្ឋកិច្ចរបស់ភូមិភាគ៤សានផងដែរ ដើម្បីបង្កើនភាពទាក់ទាញដល់វិនិយោគិន ក៏ដូចជាប្រជាពលរដ្ឋទូទៅ ឱ្យចូលមករស់នៅ និងធ្វើសកម្មភាពសេដ្ឋកិច្ចកាន់តែស្វាហាប់ឡើង និងអាចជាការអភិវឌ្ឍតំបន់ព្រំដែន ប្រកបដោយប្រសិទ្ធភាព និងនិរន្តរ-

ភាពផងដែរ។ កម្មវិធីពិសេសនេះទាមទារឱ្យមានការចូលរួមចំណែកពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ប្រកបដោយស្មារតីម្ចាស់ការ ទទួលខុសត្រូវ ជាមួយនឹងឆន្ទៈមោះមុត នៅក្នុងការរួមគ្នាបង្កើតស្នាដៃ អភិវឌ្ឍន៍ថ្មី ក្តីសង្ឃឹមថ្មី និងកម្លាំងចលករថ្មីបន្ថែមទៀត សម្រាប់លើកស្ទួយកំណើនសេដ្ឋកិច្ចជាតិ និង វិបុលភាពប្រកបដោយបរិយាប័ន្ន នៅទូទាំងប្រទេស។

«កម្មវិធីពិសេសជំរុញការវិនិយោគក្នុងខេត្តទាំងបួននៅភូមិភាគឦសាន នៃព្រះរាជាណាចក្រ-កម្ពុជា ឆ្នាំ ២០២៥-២០២៨» មានភាពទន់ភ្លន់ និងបត់បែនខ្ពស់ ដោយត្រូវបានចាត់ទុកថាជា "ឯកសាររស់" ដែលអាចនឹងកែសម្រួលបន្ថែមជាយថាហេតុ ក្នុងករណីចាំបាច់ ដើម្បីធានាសង្គតិភាព និងការឆ្លើយតបទៅនឹងកាលៈទេសៈចំពោះមុខជាក់ស្តែង ទាំងក្នុងប្រទេស, តំបន់ និង សកលលោក។ លើសពីនេះ, ការអនុវត្តកម្មវិធីពិសេសនេះ គឺជាការបង្ហាញពីឆន្ទៈនយោបាយយ៉ាងមោះមុតរបស់រាជរដ្ឋា-ភិបាល នៅក្នុងកិច្ចខិតខំប្រឹងប្រែងការពារសន្តិភាព ស្ថិរភាព ឯករាជ្យភាព និងបូរណភាពទឹកដី ក៏ដូចជា ការខិតខំពង្រីក និងចែកចាយផលលាភពីកំណើនសេដ្ឋកិច្ច ទៅដល់គ្រប់មជ្ឈដ្ឋាននៃប្រជាជនខ្មែរ ក្នុង ដំណើរឈានទៅសម្រេចមហិច្ឆតានៃការក្លាយខ្លួនជាប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ ២០៥០។

## ៨. ឧបសម្ព័ន្ធអំពីវិធានការគាំទ្រ និងជំរុញការវិនិយោគ

| I. | វិសាលភាព |
|---|---|
| ១. | ការលើកទឹកចិត្តនេះ នឹងត្រូវបានអនុវត្តចំពោះ គម្រោងវិនិយោគ ឬសកម្មភាពធុរកិច្ច ដែលបានចុះបញ្ជីជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (**គ.ល.គ.**), គម្រោងពង្រីកនៃ គ.ល.គ. ដែលមានស្រាប់, គម្រោងវិនិយោគ ឬសកម្មភាពធុរកិច្ចរបស់សហគមន៍កសិកម្មទំនើប និង គម្រោងវិនិយោគ ឬសកម្មភាពធុរកិច្ចរបស់សហគមន៍ទេសចរណ៍ ដែលត្រូវចាប់ផ្តើមដំណើរការ នៅក្នុងឆ្នាំ ២០២៥ ដល់ ២០២៨ នៅក្នុងខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តរតនគិរី ឬខេត្តមណ្ឌលគិរី។ ជាមួយគ្នានេះ, ក្នុងគោលដៅជំរុញសកម្មភាពវិនិយោគ ជាពិសេសកៀរគរមូលធនវិនិយោគក្នុងស្រុក ដើម្បីទាញយកឧត្តមប្រយោជន៍ឱ្យបានជាអតិបរមា, រាជរដ្ឋាភិបាលនឹងរៀបចំលិខិតបទដ្ឋានគតិយុត្តកំណត់លក្ខខណ្ឌបន្ធូរបន្ថយពិសេសដាច់ដោយឡែក សំដៅបើកផ្លូវឱ្យសកម្មភាពធុរកិច្ចទូទៅ (ដែលមិនមែនជា គ.ល.គ.) អាចស្នើសុំជា គ.ល.គ. ដើម្បីធ្វើការវិនិយោគនៅភូមិភាគឦសាន ក្នុងឆ្នាំ ២០២៥-២០២៨ ជាមួយនឹងការទទួលបាននូវការលើកទឹកចិត្តដូច គ.ល.គ.។<br>វិធាននៃការផ្តល់ការលើកទឹកចិត្តចំពោះ គ.ល.គ. ពាក់ព័ន្ធទៅនឹងផលិតកម្ម និងការកែច្នៃកសិផល ដែលមានលក្ខណៈជាយុទ្ធសាស្ត្រ ត្រូវតែមានសង្គតិភាព និងសម្របជាមួយនឹងក្របខណ្ឌនៃយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ក្នុងការគ្រប់គ្រង និងអភិវឌ្ឍលើមុខទំនិញយុទ្ធសាស្ត្រសំខាន់ៗ។ |
| ២. | ចំពោះគម្រោងវិនិយោគធំៗ, គម្រោងវិនិយោគ និងសកម្មភាពធុរកិច្ច ដែលមានវេទយិតភាព រួមបញ្ចូលគម្រោងដែលមានទីតាំងនៅក្បែរព្រំដែន ត្រូវអនុវត្តដោយនីតិវិធីដោយឡែក។ ចំពោះគម្រោងវិនិយោគ និងសកម្មភាពធុរកិច្ចផ្សេងទៀត ដែលស្ថិតនៅក្រៅវិសាលភាពនៃកម្មវិធីពិសេសនេះ ត្រូវដំណើរការតាមយន្តការរបស់រាជរដ្ឋាភិបាល ស្របតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងនីតិវិធីជាធរមាន។ ជាមួយគ្នានេះ, ការលើកទឹកចិត្តផ្នែកពន្ធ (ពន្ធដារ និងពន្ធគយ) ក្រោមកម្មវិធីពិសេសនេះមិនត្រូវអនុវត្ត ចំពោះសកម្មភាពវិនិយោគ និងធុរកិច្ចក្នុងវិស័យ ដូចខាងក្រោម៖<br>- ល្បែងពាណិជ្ជកម្ម;<br>- សេវាកម្ម និងអាជីវកម្មរូបិយវត្ថុ និងហិរញ្ញវត្ថុ រួមមានធនាគារ ស្ថាប័នហិរញ្ញវត្ថុ ក្រុមហ៊ុនធានារ៉ាប់រង និងប្រតិបត្តិការហិរញ្ញវត្ថុអន្តរការិយកម្មគ្រប់ប្រភេទ;<br>- កម្មន្តសាលភេសជ្ជៈ (វៀរលែងតែកម្មន្តសាលភេសជ្ជៈ ធ្វើពីផលិតផលកសិកម្ម);<br>- ការសិក្សាស្រាវជ្រាវប្រេងកាត និងរ៉ែគ្រប់ប្រភេទ;<br>- ប្រតិបត្តិការ និងអាជីវកម្មធនធានរ៉ែ និង; |

| | | |
|---|---|---|
| | ➢ សកម្មភាពលក់ដុំ និងលក់រាយទំនិញ ថ្នាំជក់ ភេសជ្ជៈ គ្រឿងស្រវឹង យានយន្តគ្រប់ប្រភេទ ប្រេងឥន្ធនៈ និងឧស្ម័ន រួមទាំងសកម្មភាពជួសជុលយានយន្ត និងទោចក្រយានយន្តគ្រប់ប្រភេទ<br>➢ សកម្មភាពវិនិយោគលើសេវាកម្មខារ៉ាអូខេ រង្គសាល បានីយដ្ឋាន កន្លែងម៉ាស្សា អាហារដ្ឋាន កន្លែងហាត់ប្រាណ តូបជួល ផ្សារលក់ដុំលក់រាយសេវាបញ្ញើ<br>➢ សកម្មភាពផ្គត់ផ្គង់អគ្គិសនីរបស់សេវាករអគ្គិសនី<br>➢ សកម្មភាពសេវាកម្មស្ថាបត្យកម្ម សេវាកម្មវិស្វកម្ម និងលទ្ធកម្មសាធារណៈ។ | |
| **II.** | **វិធានការផ្នែកពន្ធដារ និងពន្ធគយ** | **ស្ថាប័នទទួលបន្ទុក** |
| ១. | **គម្រោងវិនិយោគ ឬសកម្មភាពធុរកិច្ចជា គ.ល.គ. ក្នុងវិស័យទូទៅក្រៅពីវិស័យអាទិភាព នឹងទទួលបានការលើកទឹកចិត្តវិនិយោគ ដូចខាងក្រោម៖**<br>➢ លើកលែងពន្ធលើប្រាក់ចំណូល ប្រាក់រំដោះពន្ធលើប្រាក់ចំណូល និងពន្ធអប្បបរមា រយៈពេល ៣ ឆ្នាំបន្ថែម ដោយរយៈពេលលើកលែងពន្ធត្រូវគិតចាប់ពីឆ្នាំដែលគម្រោងវិនិយោគ ឬសកម្មភាពធុរកិច្ចមានចំណូលពីសកម្មភាពអាជីវកម្មដំបូង;<br>➢ អនុញ្ញាតឱ្យអនុវត្តអាករលើតម្លៃបន្ថែមអត្រាសូន្យភាគរយចំពោះការទិញធាតុចូលផលិតកម្ម ដែលផលិតក្នុងស្រុក;<br>➢ លើកលែងពន្ធកាត់ទុកលើការជួលអចលនទ្រព្យ ពន្ធលើផ្ទាំងផ្សព្វផ្សាយ និងពន្ធប៉ាតង់ រយៈពេល ៣ ឆ្នាំ និង;<br>➢ លើកលែងពន្ធលើប្រាក់បៀវត្សសម្រាប់កម្មករនិយោជិត ដែលទទួលបានប្រាក់បៀវត្សប្រចាំខែ ក្រោម ២ ០០០ ០០១ រៀល និងបម្រើការងារសម្រាប់ គ.ល.គ. ក្នុងខេត្តទាំងបួននៅភូមិភាគឦសាន។ | - អគ្គនាយកដ្ឋានពន្ធដារ<br>- អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា |
| ២. | **គម្រោងវិនិយោគ ឬសកម្មភាពធុរកិច្ច ក្នុងវិស័យអាទិភាព៖**<br>គ.ល.គ. ឬគម្រោងវិនិយោគ ឬសកម្មភាពធុរកិច្ច របស់សហគមន៍កសិកម្មទំនើប ក្នុងវិស័យកសិកម្ម, និង គ.ល.គ. ក្នុងវិស័យកសិ-ឧស្សាហកម្ម ស្របតាមអាទិភាពដែលបានកំណត់ ព្រមទាំង គ.ល.គ. ឬគម្រោងវិនិយោគ ឬសកម្មភាពធុរកិច្ចរបស់សហគមន៍ទេសចរណ៍ ក្នុងវិស័យទេសចរណ៍ រួមមាន ការ- | - អគ្គនាយកដ្ឋានពន្ធដារ<br>- អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា |

| | | |
|---|---|---|
| | បង្កើតតំបន់ទេសចរណ៍អត្តសញ្ញាណពិសេស, ការបង្កើតតំបន់អេកូទេសចរណ៍, ការបង្កើតតំបន់ទេសចរណ៍ពិសិដ្ឋ, ការបង្កើតសួនភូតគាម (សួនបូតានិក) ឬសួនទេសចរណ៍ ឬសួនសត្វ ឬសកម្មភាពអភិរក្សជីវៈចម្រុះ, និងការបង្កើតរមណីយដ្ឋានដែលមានសេវាកម្មចម្រុះ (រួមមានជាអាទិ៍ សេវាកម្មដូចជា សណ្ឋាគារ សួនកម្សាន្ត កន្លែងហាត់កីឡា និងសួនសត្វ) នឹងទទួលបានការលើកទឹកចិត្តវិនិយោគ ដូចខាងក្រោម៖<br>➢ លើកលែងពន្ធលើប្រាក់ចំណូល, ប្រាក់រំដោះពន្ធលើប្រាក់ចំណូល និងពន្ធអប្បបរមា រយៈពេល ១២ ឆ្នាំ ដោយរយៈពេលលើកលែងពន្ធត្រូវគិតចាប់ពីឆ្នាំដែលគម្រោងវិនិយោគ ឬសកម្មភាពធុរកិច្ចមានចំណូលពីសកម្មភាពអាជីវកម្មដំបូង;<br>➢ ចំពោះ គ.ល.គ. ឬ គម្រោងវិនិយោគឬសកម្មភាពធុរកិច្ចរបស់សហគមន៍កសិកម្មទំនើប ក្នុងវិស័យកសិកម្ម និងកសិ-ឧស្សាហកម្ម, ផ្តល់ការលើកទឹកចិត្តពន្ធគយ, អាករពិសេស និងអាករលើតម្លៃបន្ថែម ជាបន្ទុករបស់រដ្ឋលើការនាំចូលសម្ភារៈសាងសង់ បរិក្ខារសំណង់ សម្ភារៈបរិក្ខារផលិតកម្ម និងធាតុចូលផលិតកម្ម;<br>➢ ចំពោះ គ.ល.គ. ឬគម្រោងវិនិយោគ ឬសកម្មភាពធុរកិច្ចរបស់សហគមន៍ទេសចរណ៍ ក្នុងវិស័យទេសចរណ៍, ផ្តល់ការលើកទឹកចិត្តពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែម ជាបន្ទុករបស់រដ្ឋលើការនាំចូលសម្ភារៈសាងសង់ បរិក្ខារសំណង់ និងសម្ភារៈបរិក្ខារផលិតកម្ម;<br>➢ អនុញ្ញាតឱ្យអនុវត្តអាករលើតម្លៃបន្ថែមអត្រាសូន្យភាគរយចំពោះការទិញធាតុចូលផលិតកម្ម ដែលផលិតក្នុងស្រុក;<br>➢ លើកលែងពន្ធកាត់ទុកលើការជួលអចលនទ្រព្យ ពន្ធលើផ្ទាំងផ្សព្វផ្សាយ និងពន្ធប៉ាតង់ រយៈពេល ៣ ឆ្នាំ និង;<br>➢ លើកលែងពន្ធលើប្រាក់បៀវត្សសម្រាប់កម្មករនិយោជិត ដែលទទួលបានប្រាក់បៀវត្សប្រចាំខែ ក្រោម ២ ០០០ ០០១ រៀល និងបម្រើការងារសម្រាប់ គ.ល.គ. ក្នុងខេត្តទាំងបួននៅភូមិភាគឦសាន។ | |
| ៣. | **<u>គម្រោងពង្រីកនៃ គ.ល.គ. ក្នុងឆ្នាំ ២០២៥-២០២៨ នឹងទទួលបានការលើកទឹកចិត្តវិនិយោគ ដូចខាងក្រោម៖</u>** | - អគ្គនាយកដ្ឋានពន្ធដារ<br>- អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា |

| | | |
|---|---|---|
| | ➢ លើកលែងពន្ធលើប្រាក់ចំណូល ប្រាក់រំដោះពន្ធលើប្រាក់ចំណូល និងពន្ធអប្បបរមា រយៈពេល ៣ ឆ្នាំបន្ថែម ពីលើរយៈពេលជាក់លាក់ណាមួយ ទៅតាមប្រភេទក្រុមសកម្មភាពវិនិយោគដើម ផ្អែកតាមសមាមាត្រនៃអត្រាទុនពង្រីក ស្របតាមអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា;<br>➢ អនុញ្ញាតឱ្យអនុវត្តអាករលើតម្លៃបន្ថែមអត្រាសូន្យភាគរយចំពោះការទិញធាតុចូលផលិតកម្ម ដែលផលិតក្នុងស្រុក;<br>➢ លើកលែងពន្ធកាត់ទុកលើការជួលអចលនទ្រព្យ ពន្ធលើផ្ទាំងផ្សព្វផ្សាយ និងពន្ធប៉ាតង់ រយៈពេល ៣ ឆ្នាំ និង;<br>➢ លើកលែងពន្ធលើប្រាក់បៀវត្សសម្រាប់កម្មករនិយោជិត ដែលទទួលបានប្រាក់បៀវត្សប្រចាំខែ ក្រោម ២ ០០០ ០០១ រៀល និងបម្រើការងារសម្រាប់ គ.ល.គ. ក្នុងខេត្តទាំងបួននៅភូមិភាគឦសាន។<br>***<u>សម្គាល់</u>៖ និយមន័យ និងវិធីគណនាទុនពង្រីក ត្រូវអនុវត្តដូចគ្នាទៅនឹងវិធានដូចមានចែងក្នុងប្រកាសលេខ ៣១៣ សហវប្រក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៤ ស្តីពីការលើកទឹកចិត្តពន្ធលើប្រាក់ចំណូលចំពោះគម្រោងពង្រីកនៃ គ.ល.គ.។*** | |
| ៤. | **<u>សកម្មភាពធុរកិច្ច ដែលមិនទាន់បានចុះបញ្ជីពន្ធដារ៖</u>**<br>សម្រាប់សកម្មភាពធុរកិច្ច ដែលកំពុងដំណើរការ តែមិនទាន់បានចុះបញ្ជីពន្ធដារ ត្រូវទៅចុះបញ្ជីពន្ធដារតាមនីតិវិធីជាធរមានដោយស្ម័គ្រចិត្ត ក្នុងឆ្នាំ ២០២៥ នឹងទទួលបានការលើកលែង ពិន័យទោសទណ្ឌ, បំណុលពន្ធ (រួមមាន ប្រាក់ពន្ធ ពន្ធបន្ថែម និងការប្រាក់) និងការផាកពិន័យជាប្រាក់ ចំពោះការមិនបានបំពេញអនុលោមភាពកន្លងមកមុនការចុះបញ្ជីពន្ធដារដោយស្ម័គ្រចិត្ត ដែលអនុលោមតាមយុទ្ធសាស្ត្រជាតិ ស្តីពី ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឆ្នាំ ២០២៣-២០២៨។<br>ទន្ទឹមនេះ, ដើម្បីទទួលបានការលើកទឹកចិត្តបន្ថែម ដូចមានក្នុងវិធានការផ្នែកពន្ធដារ និងពន្ធគយ, សកម្មភាពធុរកិច្ច ដែលបានចុះបញ្ជីពន្ធដារដោយស្ម័គ្រចិត្ត ត្រូវចុះបញ្ជីជា គ.ល.គ. ក្នុងឆ្នាំ ២០២៥ | - អគ្គនាយកដ្ឋានពន្ធដារ<br>- អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា |

| | | |
|---|---|---|
| | ស្របតាមលិខិតបទដ្ឋានគតិយុត្តកំណត់លក្ខខណ្ឌបន្ធូរបន្ថយនៃការចុះបញ្ជីជា គ.ល.គ. ក្នុងខេត្តទាំងបួន នៅភូមិភាគឦសាន នៃកម្មវិធីពិសេស នេះ។ | |
| **III.** | **ការផ្តល់ហិរញ្ញប្បទានក្រោមអត្រាការប្រាក់សមរម្យ** | **ស្ថាប័នទទួលបន្ទុក** |
| | ការដាក់ចេញនូវកម្មវិធីហិរញ្ញប្បទានក្រោមអត្រាការប្រាក់សមរម្យ ដោយផ្តោតជាពិសេសលើសហគ្រាសធុនតូច និងមធ្យម សហគមន៍កសិកម្មទំនើប និងសហគមន៍ទេសចរណ៍ តាមរយៈធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ARDB) និងធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា (SME Bank) ដើម្បីផ្តល់ឥណទាន ក្នុងវិស័យកសិកម្ម កសិ-ឧស្សាហកម្ម និងទេសចរណ៍អាទិភាព ដែលបានកំណត់ខាងលើក្នុងគោលដៅ ១. គាំទ្រដល់ដំណើរការវិនិយោគ ឬពង្រីកអាជីវកម្ម, ២. ប្រមូលទិញ ឬស្តុកទុកកសិផល និង ៣. ជំរុញអាជីវកម្មកែច្នៃ និង/ឬ វេចខ្ចប់។ | - ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម<br>- ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា |
| **IV.** | **ការជួយកាត់បន្ថយថ្លៃដើមផលិតកម្ម, ការសម្រួលនីតិវិធី និងការគាំទ្រសកម្មភាពវិនិយោគឯកជន** | **ស្ថាប័នទទួលបន្ទុក** |
| ១. | - សម្រួលបែបបទ និងនីតិវិធីវិនិយោគ និងធុរកិច្ច រួមទាំង ការស្នើសុំអាជ្ញាបណ្ណ វិញ្ញាបនបត្រ និងលិខិតអនុញ្ញាតនានា ព្រមទាំងការចុះបញ្ជីជា គ.ល.គ.;<br>- សម្រួលនីតិវិធី បែបបទ និងការអនុញ្ញាតផ្សេងៗ សម្រាប់បម្រើដល់ការអនុវត្តគម្រោង ឬសកម្មភាពពង្រីកការវិនិយោគ និង/ឬ ធុរកិច្ច និង;<br>- ពង្រឹងយន្តការ ឬនីតិវិធីដោះស្រាយបញ្ហាប្រឈមជាក់ស្តែង ដែលជាបន្ទុកបន្ថែមរបស់វិនិយោគិនក្នុងការចុះបញ្ជី និងដំណើរការអាជីវកម្ម។ | - ក្រុមការងារអន្តរក្រសួងចំពោះកិច្ច |
| ២. | ផ្តល់ជូនការអនុគ្រោះថ្លៃប្រើប្រាស់អគ្គិសនីដូចមានក្នុងវិស័យកសិកម្ម សម្រាប់វិស័យកសិ-ឧស្សាហកម្ម រួមមានការកែច្នៃ និង/ឬ ការវេចខ្ចប់ នៃផលិតផលគន្លឹះ ជាអាទិ៍ កៅស៊ូ ស្វាយចន្ទី ដំឡូងមី ចេកអំបូងលឿង ផ្លែឈើ និងឈើដាំ។ | - អគ្គិសនីកម្ពុជា |

| | | |
|---|---|---|
| ៣. | លើកទឹកចិត្តការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគន្លឹះៗ ដើម្បីគាំទ្រដល់វិនិយោគឯកជន ក្រោមយន្តការភាព-ជាដៃគូរវាងរដ្ឋ និងឯកជនដែលមានដូចជា គម្រោងកំពង់ផែ, គម្រោងសួនកសិ-ឧស្សាហកម្ម, គម្រោងបូមស្ដារផ្លូវនាវាចរណ៍ និងគម្រោងអាកាសយានដ្ឋាន; | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ |
| ៤. | ដាក់ចេញនូវយន្តការសម្របសម្រួលក្នុងការផ្ទេរគម្រោងសម្បទានដីសេដ្ឋកិច្ចអសកម្ម ឱ្យទៅអ្នកវិនិ-យោគិនដែលមានបំណងច្បាស់លាស់ និងដាក់លាក់ក្នុងការ វិនិយោគនិងពង្រីកសកម្មភាពធុរកិច្ច លើវិស័យអាទិភាពដែលបានកំណត់ក្នុងលក្ខខណ្ឌអនុគ្រោះខ្ពស់។ | - ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>- ក្រសួងបរិស្ថាន<br>- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- រដ្ឋបាលខេត្ត |
| ៥. | អនុញ្ញាតឱ្យមានការបញ្ជាក់វិញ្ញាបនបត្រអនាម័យ និងភូតគាមអនាម័យ (Phytosanitary Certificate) ដោយអង្គភាពមានសមត្ថកិច្ចនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅខេត្តជាប់ព្រំដែនដែលមានច្រកអន្តរជាតិ។ | - ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ៦. | ពង្រឹងយន្តការផលិតកម្មកសិកម្មតាមកិច្ចសន្យា (Contract Farming) លើទំនិញកសិ-ឧស្សាហកម្មយុទ្ធសាស្ត្ររវាងអ្នកផលិត (ផ្ដល់អាទិភាពដល់សហគមន៍កសិកម្មទំនើប) និងក្រុមហ៊ុនកែច្នៃក្នុង-ស្រុក។ | - ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>- ក្រសួងពាណិជ្ជកម្ម |
| ៧. | ការពន្លឿនការចុះបញ្ជីដីធ្លី ឬប័ណ្ណកម្មសិទ្ធដីធ្លីនៅតាមតំបន់ជាយក្រុង ឬទីប្រជុំជននៃបណ្ដាខេត្តនីមួយៗ។ | - ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| ៨. | រៀបចំឱ្យមានវគ្គបណ្ដុះបណ្ដាលកិច្ចទីផ្សារឌីជីថល (Digital Marketing) និងដាក់ឱ្យអនុវត្តកម្មវិធី-បរិវត្តកម្មឌីជីថលសហគ្រាស (Enterprises Go Digital-EGD) ដើម្បីជំរុញការចូលរួមរបស់សហគ្រាសធុនតូច និងមធ្យម និងបង្កើនលទ្ធភាពក្នុងការតភ្ជាប់ជាមួយទីផ្សារ។ | - ក្រសួងប្រៃសណីយ៍ និទូរគមនាគមន៍<br>- ក្រសួងទេសចរណ៍<br>- មជ្ឈមណ្ឌលបណ្ដុះធុរកិច្ចថ្មី "តេជោ" |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ២៨ សសរ

# សេចក្តីសម្រេច
# ស្តីពី
# ការដាក់ឱ្យអនុវត្តកម្មវិធីពិសេសជំរុញការវិនិយោគក្នុងខេត្តទាំងបួន នៅតំបន់ភូមិភាគពាយ័ព្យ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០២៥-២០២៨

# រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពី ការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពី ការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពី ការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧២៣/១៥៦៣ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២៣ ស្តីពី ការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១.-**

ត្រូវបានដាក់ឱ្យអនុវត្ត «កម្មវិធីពិសេសជំរុញការវិនិយោគក្នុងខេត្តទាំងបួននៅភូមិភាគឦសាន នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០២៥-២០២៨» ដែលជាឧបសម្ព័ន្ធនៃសេចក្ដីសម្រេចនេះ។

**ប្រការ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីសេចក្ដីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១កើត ខែ ផល្គុន ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ ២០២៥

**នាយករដ្ឋមន្ត្រី**

ព្រះរាជាណាចក្រកម្ពុជា គណៈរដ្ឋមន្ត្រី

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

<u>កន្លែងទទួល</u> ៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្ដមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៣៩ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារជំរុញការវិនិយោគក្នុងភូមិភាគឦសាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧២៣/១៥៦៣ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញសេចក្តីសម្រេចលេខ ២៨ សសរ ចុះថ្ងៃទី ២៧ ខែកុម្ភៈ ឆ្នាំ២០២៥ ស្តីពីការដាក់ឱ្យអនុវត្តកម្មវិធីពិសេសជំរុញការវិនិយោគក្នុងខេត្តទាំងបួននៅភូមិភាគឦសាន នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០២៥-២០២៨
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើត «**ក្រុមការងារជំរុញការវិនិយោគក្នុងភូមិភាគឦសាន**» សរសេរជាអក្សរកាត់ថា **ក.ខ.ឦសាន** ក្រោមឆ័ត្រ គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (គ.ស.ហ.) ដែលមានសមាសភាព ដូចខាងក្រោម ៖

| | | |
|---|---|---|
| ១. ឯកឧត្តមបណ្ឌិតសភាចារ្យ **ហ៊ាន សាហ៊ីប** | ទីប្រឹក្សាសម្តេចធិបតីនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ក.ស.ហ.វ.) | ប្រធាន |
| ២. ឯកឧត្តមបណ្ឌិត **ផាន់ ផល្លា** | រដ្ឋលេខាធិការ ក.ស.ហ.វ. និងជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ស.ហ. | អនុប្រធាន |
| ៣. ឯកឧត្តម **ស៊ឹម វីរៈ** | អនុរដ្ឋលេខាធិការ ក.ស.ហ.វ. និងជាអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ស.ហ. | អនុប្រធានប្រចាំការ |
| ៤. ឯកឧត្តម **យុន ហេង** | អគ្គលេខាធិការរង គណៈកម្មាធិការវិនិយោគកម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | អនុប្រធាន |
| ៥. ឯកឧត្តម **ផាន់ ចាន់ធុល** | រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | សមាជិក |
| ៦. ឯកឧត្តម **រស់ សុវែន** | រដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៧. ឯកឧត្តម **ធូ ផារិទ្ធ** | រដ្ឋលេខាធិការ ក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ៨. ឯកឧត្តម **ម៉ែន សុទិជាតិ** | រដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៩. ឯកឧត្តម **យស មុនីរ៉ាត់** | រដ្ឋលេខាធិការ ក្រសួងរ៉ែ និងថាមពល | សមាជិក |
| ១០. លោកជំទាវ **សេង វណ្ណឡាត** | រដ្ឋលេខាធិការ ក្រសួងផែនការ | សមាជិក |
| ១១. ឯកឧត្តម **សៅ សុភាព** | រដ្ឋលេខាធិការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ១២. ឯកឧត្តម **សូ ខនឫទ្ធីគុណា** | រដ្ឋលេខាធិការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ១៣. ឯកឧត្តម **ម៉ុង មុនីណា** | រដ្ឋលេខាធិការ ក្រសួងបរិស្ថាន | សមាជិក |
| ១៤. ឯកឧត្តម **តុប សុភ័ក** | រដ្ឋលេខាធិការ ក្រសួងទេសចរណ៍ | សមាជិក |
| ១៥. ឯកឧត្តម **ចាប ឫទ្ធី** | រដ្ឋលេខាធិការ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១៦. ឯកឧត្តម **ពេជ្រ សម្បត្តិ** | អនុរដ្ឋលេខាធិការ ក.ស.ហ.វ. | សមាជិក |
| ១៧. ឯកឧត្តម **ហ៊ិត ផេង** | អនុរដ្ឋលេខាធិការ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សមាជិក |
| ១៨. ឯកឧត្តម **ម៉ៅ សិលា** | អនុរដ្ឋលេខាធិការ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ១៩. ឯកឧត្តម **ស៊ឹង សុគង់** | អនុរដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ២០. ឯកឧត្តម **ទ្រី ដាលុច** | អគ្គលេខាធិការរង គណៈកម្មាធិការវិនិយោគកម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |

| | | |
|---|---|---|
| ២១. ឯកឧត្តម **អ៊ុំ លុយណា** | អគ្គនាយក នៃអគ្គនាយកដ្ឋានគោលនយោបាយ ក.ស.ហ.វ. | សមាជិក |
| ២២. ឯកឧត្តម **ឱម ម៉ាក់ឆារិទ្ធ** | អគ្គនាយក នៃអគ្គនាយកដ្ឋានភាពជាដៃគូរវាងរដ្ឋ និងឯកជន ក.ស.ហ.វ. | សមាជិក |
| ២៣. ឯកឧត្តមបណ្ឌិត **កៅ ថាច** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម | សមាជិក |
| ២៤. ឯកឧត្តម **រ័ត្ន មុនី** | អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ ក.ស.ហ.វ. | សមាជិក |
| ២៥. ឯកឧត្តម **ថង សាវុន** | អភិបាល នៃគណៈអភិបាលខេត្តមណ្ឌលគិរី | សមាជិក |
| ២៦. ឯកឧត្តម **ញ៉ែម សំអឿន** | អភិបាល នៃគណៈអភិបាលខេត្តរតនគិរី | សមាជិក |
| ២៧. ឯកឧត្តម **វ៉ា ថន** | អភិបាល នៃគណៈអភិបាលខេត្តក្រចេះ | សមាជិក |
| ២៨. ឯកឧត្តម **សរ សុព្រត្រា** | អភិបាល នៃគណៈអភិបាលខេត្តស្ទឹងត្រែង | សមាជិក |
| ២៩. លោក **ជា សុភ័ក្ក** | អគ្គនាយកស្តីទី ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា | សមាជិក |
| ៣០. លោកបណ្ឌិត **ឆូច សុមេធា** | អគ្គនាយករង នៃអគ្គនាយកដ្ឋានគោលនយោបាយ ក.ស.ហ.វ. | សមាជិក |
| ៣១. លោក **ផា អេងម៉េង** | អគ្គនាយករង នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក.ស.ហ.វ. | សមាជិក |
| ៣២. លោក **ម៉ែត សុខន** | អគ្គនាយករងហិរញ្ញកិច្ច-អាជីវកម្ម នៃអគ្គិសនីកម្ពុជា | សមាជិក |
| ៣៣. លោក **ឈឹម ចន្ទរតនៈ** | អនុប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ និងខេត្ត នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ | សមាជិក |
| ៣៤. លោក **ត្រាំង ឡៃ** | អនុប្រធាននាយកដ្ឋានសវនកម្មសហគ្រាស នៃអគ្គនាយកដ្ឋានពន្ធដារ ក.ស.ហ.វ. | សមាជិក |
| ៣៥. លោក **សុខ កុសល** | អនុប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ នៃអគ្គនាយកដ្ឋានពន្ធដារ ក.ស.ហ.វ. | សមាជិក។ |

**ប្រការ២.-**

**គ.ទ.ឦ្យសាន** មានភារកិច្ច ដូចខាងក្រោម ៖

- ដឹកនាំ សម្របសម្រួល និងអនុវត្ត «កម្មវិធីពិសេសជំរុញការវិនិយោគក្នុងខេត្តទាំងបួននៅភូមិភាគឦសាន នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០២៥-២០២៨» ដោយដើរតួនាទីជា "ច្រកចេញចូលតែមួយ" ដែលមានតួនាទីពិនិត្យ វាយតម្លៃ និងផ្តល់ការអនុម័តគម្រោងវិនិយោគ, និងផ្តល់លិខិតអនុញ្ញាត ឬអាជ្ញាបណ្ណនានាជាកញ្ចប់ សម្រាប់ទទួលបាននូវការលើកទឹកចិត្ត និងការអនុគ្រោះនានាពីរាជរដ្ឋាភិបាល ដែលស្ថិតក្រោមវិសាលភាពនៃកម្មវិធីពិសេស
- ពិនិត្យ និងស្នើសុំការដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្តចាំបាច់នានា តាមរយៈ គ.ស.ហ.
- រៀបចំឯកសារចាំបាច់នានា និងនីតិវិធីអនុវត្តការងាររបស់ក្រុមការងារ និងធ្វើកិច្ចសហការល្អជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ
- ផ្សព្វផ្សាយជាសាធារណៈនូវកម្មវិធីពិសេសឱ្យបានទូលំទូលាយ, ធ្វើការពន្យល់ឱ្យបានច្បាស់លាស់ និងត្រឹមត្រូវ, និងផ្តល់សេវាបដិសណ្ឋារកិច្ច និងកិច្ចសហការល្អជាមួយវិនិយោគិន និងធុរជន ទាំងក្នុង និងក្រៅប្រទេស

- ដាក់ចេញកម្មវិធីពង្រឹងសមត្ថភាពដល់ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញ ព្រមទាំងអ្នកពាក់ព័ន្ធ ដោយផ្តោតលើការបំពេញភារកិច្ច, ការសម្របសម្រួល, ការផ្តល់សេវាដល់វិនិយោគិន និងធុរជន, ការរៀបចំគម្រោង, និងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ដើម្បីផ្តល់សេវា និងអនុវត្តការងារប្រកបដោយគណនេយ្យភាព តម្លាភាព និងប្រសិទ្ធភាព
- រៀបចំ និងអនុវត្តផែនការសកម្មភាព និងក្របខណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ការអនុវត្តកម្មវិធីពិសេស
- រៀបចំកិច្ចប្រជុំក្រុមការងាររៀងរាល់ត្រីមាស ឬកិច្ចប្រជុំណាមួយតាមការចាំបាច់ ដើម្បីដោះស្រាយបញ្ហាប្រឈម, ដាក់ចេញវិធានការកែតម្រូវ, វាស់វែងពីការខិតខំប្រឹងប្រែង, និងវាយតម្លៃប្រសិទ្ធភាព និងលទ្ធផលនៃកម្មវិធីពិសេស
- រៀបចំរបាយការណ៍វឌ្ឍនភាព និងការវាយតម្លៃការអនុវត្តកម្មវិធីពិសេស ប្រចាំឆ្នាំ ជូនរាជរដ្ឋាភិបាល តាមរយៈ គ.ស.ហ.
- អនុវត្តនូវកិច្ចការ ឬបំពេញភារកិច្ចដទៃទៀត តាមការសម្រេចរបស់ គ.ស.ហ. ឬតាមការសម្រេចរបស់រាជរដ្ឋាភិបាល។

**ប្រការ៣.-**

ប្រធាន **គ.ខ.ឡាំសាន** ទទួលខុសត្រូវរួមក្នុងការដឹកនាំក្រុមការងារ និងដឹកនាំកិច្ចប្រជុំ។ ប្រធានអាចចាត់តាំងអនុប្រធាន ឬសមាជិកក្រុមការងារ ដឹកនាំការងារជំនួសក្នុងករណីចាំបាច់ ឬប្រធានអវត្តមាន។ សមាជិក **គ.ខ.ឡាំសាន** ត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ប្រធាន ឬអនុប្រធានណាមួយ ក្នុងករណីដែលប្រធានអវត្តមាន ឬមានករណីចាំបាច់។

**ប្រការ៤.-**

គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ត្រូវធ្វើប្រតិភូកម្មសិទ្ធិអំណាចជូនសមាជិកនៃ **គ.ខ.ឡាំសាន** ដែលជាមន្ត្រីរបស់ក្រសួង-ស្ថាប័នខ្លួន ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ដើម្បីសម្រេចលើកិច្ចការពាក់ព័ន្ធដល់ការចេញលិខិតអនុញ្ញាត អាជ្ញាបណ្ណនានា ក្នុងការចុះបញ្ជីគម្រោងវិនិយោគ, ការផ្តល់ការលើកទឹកចិត្ត, ការធានា, ការទិញ ការលក់ ការរួមបញ្ចូលគ្នា និងការលុបគម្រោង, និងការដោះស្រាយវិវាទវិនិយោគ ដែលស្ថិតក្រោមវិសាលភាពនៃកម្មវិធីពិសេស។

**ប្រការ៥.-**

**គ.ខ.ឡាំសាន** មានធនធានហិរញ្ញវត្ថុក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**គ.ខ.ឡាំសាន** មានសិទ្ធិប្រើប្រាស់ត្រាក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់បំពេញភារកិច្ច ទាំងតាមទម្រង់ច្បាប់ដើម និងតាមប្រព័ន្ធអេឡិចត្រូនិក។

**ប្រការ៦.-**

**គ.ទ.ព្លាំសាន** មានសិទ្ធិអញ្ជើញតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ដែលទទួលបានប្រតិភូកម្ម ឬ មានសិទ្ធិសម្រេច ក្នុងនាមជាប្រធានស្ថាប័ន តាមការចាំបាច់ ដើម្បីចូលរួមអនុវត្តកម្មវិធីពិសេស។

**គ.ទ.ព្លាំសាន** មានសិទ្ធិអញ្ជើញ ស្ថាប័នស្រាវជ្រាវ វិស័យឯកជន ដៃគូអភិវឌ្ឍន៍ និងជំនាញការ ដើម្បីផ្តល់ព័ត៌មាន និងយោបល់នានា សម្រាប់គោលបំណងសិក្សាស្រាវជ្រាវ និងរៀបចំគម្រោង ដែលស្ថិតក្រោមវិសាលភាពនៃកម្មវិធីពិសេស។

**គ.ទ.ព្លាំសាន** មានសិទ្ធិជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា ដើម្បីរៀបចំ ត្រួតពិនិត្យ និងវាយតម្លៃគម្រោង ដែលស្ថិតក្រោមវិសាលភាពនៃកម្មវិធីពិសេស និងបំពេញភារកិច្ចដទៃទៀត តាមការណែនាំរបស់ប្រធាន **គ.ទ.ព្លាំសាន**។

**ប្រការ៧.-**

**គ.ទ.ព្លាំសាន** មានលេខាធិការដ្ឋានមួយជាសេនាធិការ។ លេខាធិការដ្ឋាន **គ.ទ.ព្លាំសាន** មានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| ១. ឯកឧត្តម **ស៊ឹម ទីរៈ** | អនុរដ្ឋលេខាធិការ ក.ស.ហ.វ. និងជាអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ស.ហ. | ប្រធាន |
| ២. ឯកឧត្តម **ពេជ្រ សម្បត្តិ** | អនុរដ្ឋលេខាធិការ ក.ស.ហ.វ. | អនុប្រធាន |
| ៣. លោក **សុ សោភ័ណទិចិត្រ** | អនុប្រធាននាយកដ្ឋានប្រសិទ្ធភាពចំណាយ ក.ស.ហ.វ. និងជាជំនួយការស្រាវជ្រាវនៃអគ្គលេខាធិការដ្ឋាន គ.ស.ហ. | អនុប្រធាន |
| ៤. លោក **ម៉ិន ឌីទ** | ប្រធាននាយកដ្ឋានរបបគយ នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក.ស.ហ.វ. | សមាជិក |
| ៥. លោក **ម៉ែន គុខ** | នាយករងរដ្ឋបាល នៃរដ្ឋបាលខេត្តស្ទឹងត្រែង | សមាជិក |
| ៦. លោក **កុយ រតនា** | នាយកទីចាត់ការផែនការ និងវិនិយោគ នៃរដ្ឋបាលខេត្តមណ្ឌលគិរី | សមាជិក |
| ៧. លោក **ឡេខ តា** | នាយកទីចាត់ការផែនការ និងវិនិយោគ នៃរដ្ឋបាលខេត្តរតនគិរី | សមាជិក |
| ៨. លោក **សាមុត លីម៉ា** | នាយកទីចាត់ការផែនការ និងវិនិយោគ នៃរដ្ឋបាលខេត្តក្រចេះ | សមាជិក |
| ៩. លោក **ផេខ អ៊ី** | អនុប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នៃអគ្គលេខាធិការដ្ឋាន ក.ស.ហ.វ. | សមាជិក |
| ១០. លោក **ខាំ គុខ** | ប្រធានការិយាល័យវិនិយោគ នៃរដ្ឋបាលខេត្តរតនគិរី | សមាជិក |
| ១១. លោក **ប្រាជ្ញ ឡឿន** | អនុប្រធានការិយាល័យសម្ភារ និងទ្រព្យសម្បត្តិរដ្ឋ នៃនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នៃអគ្គលេខាធិការដ្ឋាន ក.ស.ហ.វ. | សមាជិក |

១២. លោក **ស៊ូ វាសនា** អនុប្រធានការិយាល័យសម្ភារ និងទ្រព្យសម្បត្តិរដ្ឋ នៃនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នៃអគ្គលេខាធិការដ្ឋាន ក.ស.ហ.វ. សមាជិក

១៣. លោក **ស្រី លីហ្សា** អនុប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានគោលនយោបាយ ក.ស.ហ.វ. សមាជិក

១៤. លោក **មេ ម៉េងអ៊ី** អនុប្រធានការិយាល័យ នៃនាយកដ្ឋាននីតិកម្ម គោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការពន្ធដារអន្តរជាតិ នៃអគ្គនាយកដ្ឋានពន្ធដារ ក.ស.ហ.វ. សមាជិក

១៥. ប្រធានសាខាគយ និងរដ្ឋាករខេត្តក្រចេះ នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក.ស.ហ.វ. សមាជិក

១៦. ប្រធានសាខាគយ និងរដ្ឋាករខេត្តស្ទឹងត្រែង នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក.ស.ហ.វ. សមាជិក

១៧. ប្រធានសាខាគយ និងរដ្ឋាករខេត្តរតនគិរី នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក.ស.ហ.វ. សមាជិក

១៨. ប្រធានសាខាគយ និងរដ្ឋាករខេត្តមណ្ឌលគិរី នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក.ស.ហ.វ. សមាជិក

១៩. លោក **ស៊ាន មនោរិទ្ធ** មន្ត្រីនៃអគ្គនាយកដ្ឋានគោលនយោបាយ ក.ស.ហ.វ. សមាជិក

២០. លោក **អ៊ឹម ស៊ុនហេង** មន្ត្រីនៃអគ្គនាយកដ្ឋានថវិកា ក.ស.ហ.វ. សមាជិក

២១. លោក **ថង ណារង្សុខ** មន្ត្រីនៃអគ្គលេខាធិការដ្ឋាន ក.ស.ហ.វ. សមាជិក

២២. លោក **ឃឹម ពិសាល** មន្ត្រីនៃនាយកដ្ឋានវិភាគគម្រោង និងការលើកទឹកចិត្ត គណៈកម្មាធិការវិនិយោគកម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក

២៣. លោក **សំអោគ ច័ន្ទសុមានិត** ជំនួយការអគ្គលេខាធិការរង គណៈកម្មាធិការវិនិយោគកម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក

២៤. លោក **អ៊ុង បញ្ញា** ជំនួយការស្រាវជ្រាវនៃអគ្គលេខាធិការដ្ឋាន គ.ស.ហ. សមាជិក

២៥. កញ្ញា **ខូច មួយឡេង** ជំនួយការស្រាវជ្រាវនៃអគ្គលេខាធិការដ្ឋាន គ.ស.ហ. សមាជិក

២៦. លោក **ខាន់ លីហួរ** ជំនួយការស្រាវជ្រាវនៃអគ្គលេខាធិការដ្ឋាន គ.ស.ហ. សមាជិក

២៧. កញ្ញា **តូ សុធារតន៍** ជំនួយការស្រាវជ្រាវនៃអគ្គលេខាធិការដ្ឋាន គ.ស.ហ. សមាជិក

២៨. លោក **សុខ សុធារៈ** ជំនួយការស្រាវជ្រាវនៃអគ្គលេខាធិការដ្ឋាន គ.ស.ហ. សមាជិក

២៩. លោកស្រី **ឈួ គីមនាង** ជំនួយការស្រាវជ្រាវនៃអគ្គលេខាធិការដ្ឋាន គ.ស.ហ. សមាជិក។

**ប្រការ៨.-**

លេខាធិការដ្ឋាន **គ.ទ.ព្ធ្ញសាន** ដើរតួនាទីសម្របសម្រួលផ្នែករដ្ឋបាលទាំងអស់ និងមានការិយាល័យនៅរាជធានីភ្នំពេញ និងអាចបង្កើតការិយាល័យតាមបណ្ដាខេត្តនៅភូមិភាគឦសាន តាមការចាំបាច់។ លេខាធិការដ្ឋាន **គ.ទ.ព្ធ្ញសាន** មានភារកិច្ចដូចខាងក្រោម ៖

- ផ្ដល់សេវាគាំទ្រ និងបំពេញការងារ សម្រាប់ប្រក្រតីភាពនៃកិច្ចដំណើរការប្រចាំថ្ងៃ របស់ **គ.ទ.ព្ធ្ញសាន**
- សម្របសម្រួលកិច្ចទំនាក់ទំនងសាធារណៈ ប្រឹក្សាយោបល់ ផ្សព្វផ្សាយ ទាក់ទាញ និងធ្វើបដិសណ្ឋារកិច្ច ដល់វិនិយោគិន ធុរជន និងអ្នកផ្សេងទៀតដែលមានការពាក់ព័ន្ធ

- ពិនិត្យ ប្រមូលធាតុចូល វិភាគ និងវាយតម្លៃលើគម្រោងវិនិយោគដែលបានស្នើសុំ ដើម្បីទទួលបាននូវការ-លើកទឹកចិត្ត និងការអនុគ្រោះនានាពីរាជរដ្ឋាភិបាល ដែលស្ថិតក្រោមវិសាលភាពនៃកម្មវិធីពិសេស ព្រមទាំងលើកយោបល់ជូន **ក.ទ.ឦសាន** ដើម្បីពិនិត្យ និងសម្រេចអនុម័តគម្រោងវិនិយោគទាំងនោះ
- រៀបចំផែនការសកម្មភាពរបស់លេខាធិការដ្ឋាន **ក.ទ.ឦសាន** ដើម្បីគាំទ្រ និងជំរុញការអនុវត្តកម្មវិធីពិសេសប្រកបដោយប្រសិទ្ធភាព ព្រមទាំងរៀបចំរបាយការណ៍វឌ្ឍនភាពការងារ
- បំពេញភារកិច្ចដទៃទៀតតាមការសម្រេចរបស់ប្រធាន **ក.ទ.ឦសាន**។

**ប្រការ៩.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១០.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ១៤កើត ខែ ផល្គុន ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

<u>**កន្លែងទទួល ៖**</u>
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ